ព្រលឹងខ្មែរ
www.amekhmer.fr

ទក្ខទស្វី
សម្លេងខ្មែរនៅបរទេស

# សីហនុនិងជំនួយអាមេរិកាំង

ដោយ លី-ឡៀប ★ ថ្ងៃទី២ ឧសភា ២០០៤

ខាងក្រោមនេះជាអត្ថបទរបស់ស្តេចសីហនុ ខ្ទាល់នឹងកូនសិស្សម្នាក់សរសេរអ៊ីមែលទិតៀនព្រះអង្គភូតកុហក ថាមិនដែលបានទទួលជំនួយអាមេរិកាំង ៖

**អត្ថបទប្រចាំថ្ងៃទី៧ របស់ខ្ញុំ សំរាប់ថ្ងៃទី ខែឧសភា ឆ្នាំ២០០៤**

ជនរួមជាតិ បងប្អូន កូនចៅ ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ថ្មីៗនេះមាននិស្សិតម្នាក់បានសរសេរអ៊ីមែលក្នុងនាមមិត្តភ័ក្ត្រគេជាច្រើននាក់ មកទិតៀន ថាខ្ញុំជាមហាក្សត្រចេះភូតភរកុហក ដោយនិយាយថាមិនដែលបានទទួលជំនួយអាមេរិកាំងពីមុននោះទេ ។ ខ្ញុំមានការឈឺចាប់ពន់ប្រមាណចំពោះការសរសេរប្រមាថខ្ញុំដែលមានជន្មាយុ៨២វស្សាហើយ ពីសំណាក់បញ្ញាវ័នមួយក្រុមនោះ ។

ខ្ញុំមានការសោកស្តាយជាពន់ពេកណាស់ចំពោះបញ្ញាវ័នមួយក្រុមនេះដែលមានទោសៈមោហៈប្រព្រឹត្តិអំពើអយុត្តិធម៌ចំពោះមហាក្សត្រខ្លួន ប្រាសចាកសីលធម៌ សច្ចធម៌ដែលគ្រូបាធ្យាយលោកបានអប់រំខ្លួននៅបឋមសិក្សា វិទ្យាល័យ និងសកលវិទ្យាល័យ ។

តើការពិតវាយ៉ាងដូចម្តេច ?

ខ្ញុំសូមបញ្ជាក់ជូនជនរួមជាតិ បងប្អូន កូនចៅ ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុតបានជ្រាបដូចតទៅ :

ពីឆ្នាំ១៩៥៥ មកដល់ឆ្នាំ១៩៦៣ កម្ពុជា(មិនមែន នរោត្តម សីហនុ ទេ ដែលទទួលជំនួយនោះ ។ ខ្ញុំមិនដែលទទួលលុយពីអ្នកណាម្នាក់ទេ ។ ខ្ញុំស្អប់ណាស់ ហើយប្រយុទ្ធនឹងអំពើពុករលួយដែលជាហេតុនាំឱ្យគេគុំគួនខ្ញុំ ហើយទម្លាក់ខ្ញុំ ។ ) បានទទួលជំនួយពីអាមេរិកាំងក្នុង១ឆ្នាំ គិតសារុបទាំងអស់៣០លានដុល្លារអាមេរិក។ ជំនួយ៣០លានដុល្លារអាមេរិកដែលសហរដ្ឋអាមេរិកផ្តល់ដល់កម្ពុជានេះ គេមិនមែនផ្តល់ជាទឹកប្រាក់នោះទេ គឺគេបូកសព្វគ្រប់អំពីដម្លៃបរិក្ខាផ្សេងៗ មានដម្លៃអាគារដែលគេជួយសាងសង់ ដម្លៃផ្លូវថ្នល់ រថយន្ត គ្រាប់កាំភ្លើង អាវុធយុទ្ធភ័ណ្ឌ។ ល។ ដែលសហរដ្ឋអាមេរិកជួយដល់វិស័យអប់រំ វិស័យសុខាភិបាល វិស័យផ្សេងៗទៀត ជាពិសេសជួយខាងផ្នែកយោធាច្រើនជាងគេ ។

ខ្ញុំបានសរសេរជំរាបជាតិជាភាសាបារាំងនៅក្នុងឆ្នាំ១៩៦៣ ស្តីអំពីជំនួយអាមេរិកផ្តល់ដល់កម្ពុជាដែលមានចំណង និងមានល័ក្ខខ័ណ្ឌគ្រប់បែបយ៉ាង ។

ចំណង និងល័ក្ខខ័ណ្ឌដែលសហរដ្ឋអាមេរិកដាក់មកលើយើង ធ្វើឱ្យយើងអាម៉ាស់មុខ ប៉ះពាល់ដល់ឯករាជ្យ សេចក្តីថ្លៃថ្នូរ និងកិត្តិយសជាតិយើង ។ ដោយឈរលើហេតុផលទាំងអស់នេះហើយទើបខ្ញុំសំរេចក្នុងឋានៈខ្ញុំជាប្រមុខរដ្ឋ និងប្រធានសង្គមរាស្ត្រនិយមដែលប្រជារាស្ត្រជាម្ចាស់ឆ្នោតលោកបានបោះឆ្នោតឱ្យកាន់អំណាច ទាត់ជំនួយមានចំណង និងល័ក្ខខ័ណ្ឌគ្រប់បែបយ៉ាងរបស់អាមេរិក ចាប់អំពីពេលនេះតទៅ ហើយឈប់ទទួលយកមកវិញហើយជំនួយបែបនេះ។ ការកាត់ជំនួយនេះបានធ្វើឱ្យពួកលន់ ណុល សិរីមតៈ ដែលមានសេអ៊ីអាជួយ សំរេចថាត្រូវធ្វើរដ្ឋប្រហារទម្លាក់ខ្ញុំនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ នៅក្នុងឱកាសដែលខ្ញុំកំពុងបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅសហភាពសូវៀត ។

បើខ្ញុំនិយាយថាទាត់ចោលជំនួយអាមេរិកាំងនៅឆ្នាំ១៩៦៣ គឺបានសេចក្តីថាកម្ពុជាបានទទួលជំនួយគាត់ ទើបខ្ញុំអាចសំរេចថាឈប់ទទួលជំនួយនោះកើត ហើយការនេះអ្នកមិនបានសិក្សាជ្រៅជ្រះក៏គង់តែយល់ច្បាស់លាស់ដែរ ។ ក្រុមបញ្ញាវ័នមួយក្រុមនេះហ៊ានភូតកុហក់ខ្លួន ដោយគ្មានសតិសម្បជញ្ញៈអ្វីបន្តិចទាល់តែសោះ ចោទប្រកាន់ខ្ញុំដោយអយុត្តិធម៌ ផ្សព្វផ្សាយនូវការមិនពិតខាងលើតាមអ៊ិនធ័រណែត និងអ៊ីមែលដើម្បីបន្ទាបបន្ថោកខ្ញុំដែលក្នុងមួយជីវភាពនេះ ខ្ញុំបានបំរើប្រជាជាតិមាតុភូមិ និងប្រជារាស្ត្រកម្ពុជាជាងកន្លះសតវត្សរ៍មកហើយៗតែងតែស្មោះត្រង់ជានិច្ចចំពោះជាតិមាតុភូមិ ព្រះសង្ឃ និងប្រជារាស្ត្រកម្ពុជា ។

ខ្ញុំបានផ្សព្វផ្សាយជារៀងរាល់ថ្ងៃ មួយថ្ងៃមួយអត្ថបទនូវព្រឹត្តិការណ៍ដែលកើតមាននៅកម្ពុជា នាឆ្នាំ១៩៦៣ ។ អត្ថបទប្រចាំថ្ងៃរបស់ខ្ញុំនេះ សំរាប់ជូនជាតិ និងជនរួមជាតិ បងប្អូន កូនចៅ ចៅទួតបានជ្រាបអំពីរឿងប្រវត្តិសាស្ត្រតូច មធ្យម និងធំ ដែលកើតមាននៅកម្ពុជាយើង ហើយខ្ញុំគ្មានបំណងប្តឹងអ្នកណាម្នាក់ទេ ។

សូមជនរួមជាតិ បងប្អូន កូនចៅ ចៅទួតទាំងអស់ ទទួលនូវសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត អំពីខ្ញុំ ។

រឿងជំនួយអាមេរិកាំងនេះ ជារឿងចាស់ទេតើ ។ យើងមិនដឹងថា តើកូនសិស្សដដែលជាអ្នកផ្ញើអ៊ីមែលមកស្តេចសីហនុ ឬក៏ជាកូនសិស្សថ្មីទៀយ តែដែលយើងបានដឹងនោះ គឺបន្ទាប់ពីជេរកូនសិស្សនេះថា ជាក្មេងឥតមានអ្នកណាប្រៀនប្រដៅមក ស្តេចសីហនុបាន«មួលសំដី»របស់ព្រះអង្គសារជាថ្មីទៀត ៖ «ខ្ញុំសូមបញ្ជាក់ជូនជនរួមជាតិ បងប្អូន ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុតបានជ្រាបដូចតទៅ ៖ ពីឆ្នាំ១៩៥៥ មកដល់ឆ្នាំ១៩៦៣ កម្ពុជា (មិនមែននរោត្តម-សីហនុទេ ដែលទទួលជំនួយនោះ ។ ខ្ញុំមិនដែលទទួលលុយពីនរណាម្នាក់ទេ ។ ខ្ញុំស្អប់ណាស់ ហើយប្រយុទ្ធនឹងអំពើពុករលួយដែលជាហេតុនាំឲ្យគេគុំគួនខ្ញុំហើយទម្លាក់ខ្ញុំ ) » (sic) ។

ព្រះអង្គមានបន្ទូលថា ៖ ពុំមែនជាព្រះអង្គទេ ដែលជា«អ្នកទទួលជំនួយ»នោះ គឺ«កម្ពុជា»ទេតើដែលជាអ្នកទទួល (!!)

ហោ! ហោ! តើនរណាទៅនិយាយថា ស្តេចសីហនុជាអ្នកទទួលជំនួយនេះនោះ ? ។ តើឯកសារត្រង់ណាដែលបញ្ជាក់ថា អាមេរិកាំងផ្តល់ជំនួយឯកជន ទៅបុគ្គលឈ្មោះ នរោត្តម-សីហនុ ? ។ គ្មានទេ (!!) គ្មានទាល់តែសោះ (!!) ។ ជំនួយអាមេរិកាំងទាំងអស់នោះ គឺផ្តល់ជូនទៅឲ្យរាជរដ្ឋាភិបាលខ្មែរ ដែលមាននរោត្តម-សីហនុជា«ប្រមុខរដ្ឋ»... នេះជាការពិតឥតប្រកែកបានឡើយ (!!) ឬមួយស្តេចសីហនុយល់ថា ទាល់តែអាមេរិកាំងឲ្យ«លុយ»មកព្រះអង្គ ក្នុងមួយឆ្នាំ«៣០លានដុល្លារ» ទើបបានហៅថាព្រះអង្គជាអ្នកទទួលជំនួយទាំងអស់នោះឬ ? ។ ពុទ្ធោអរហំ !!

ស្តេចសីហនុសរសេរថា ៖ «ជំនួយ៣០លានដុល្លារអាមេរិកដែលសហរដ្ឋអាមេរិកផ្តល់ដល់កម្ពុជានេះ គេមិនមែនផ្តល់ជាទឹកប្រាក់ទេ គឺគេបូកសព្វគ្រប់អំពីតម្លៃបរិក្ខាផ្សេងៗ មានតម្លៃអាគារដែលគេជួយសាងសង់តម្លៃផ្លូវថ្នល់ រថយន្ត គ្រាប់កាំភ្លើង អាវុធយុទ្ធភ័ណ្ឌ ។ល។ ដែលសហរដ្ឋអាមេរិកជួយដល់វិស័យអប់រំ វិស័យសុខាភិបាល វិស័យផ្សេងៗទៀតជាពិសេសជួយខាងផ្នែកយោធាច្រើនជាងគេ» ។

ស្តេចសីហនុសរសេរបន្តថា ៖ «ខ្ញុំបានសរសេរជំរាបជាតិជាភាសាបារាំងនៅក្នុងឆ្នាំ១៩៦៣ ស្តីអំពីជំនួយអាមេរិកផ្តល់ដល់កម្ពុជាដែលមានចំណង និងមានល័ក្ខខ័ណ្ឌគ្រប់បែបយ៉ាង ។ ចំណងនិងល័ក្ខខ័ណ្ឌដែលសហរដ្ឋអាមេរិកដាក់មកលើយើង ធ្វើឲ្យយើងអាម៉ាស់មុខ ប៉ះពាល់ដល់ឯករាជ្យ សេចក្តីថ្លៃថ្នូរ និងកិត្តិយសជាតិយើង ។ ដោយឈរលើហេតុផលទាំងអស់នេះហើយ ទើបខ្ញុំសំរេចក្នុងឋានៈខ្ញុំជាប្រមុខរដ្ឋ និងប្រធានសង្គមរាស្ត្រនិយមដែលប្រជារាស្ត្រជាម្ចាស់ឆ្នោតលោកបានបោះឆ្នោតឲ្យកាន់អំណាច ទាត់ជំនួយមានចំណង និងល័ក្ខខ័ណ្ឌគ្រប់បែបយ៉ាងរបស់អាមេរិក ចាប់អំពីពេលនេះតទៅ ហើយឈប់ទទួលមកវិញហើយជំនួយបែបនេះ» ។

គិតទៅម៉្យាងដែរតើ ! នៅពេលទទួលជំនួយអាមេរិកាំង ស្តេចសីហនុចង្អុលថា ព្រះស្តែងមិនបានទទួលទេ គឺ«កម្ពុជា»ទេតើជាអ្នកទទួល ។ តែដល់ពេលកាត់ផ្តាច់ ត្រឡប់ជាព្រះស្តែងខ្លួនឯងទៅវិញជាអ្នកធ្វើ ។

បន្ថែមពីលើនេះទៀត, ស្តេចសីហនុនិយាយថា មូលហេតុដែលព្រះស្តែងកាត់ផ្តាច់ គឺដោយសារមកពី «ជាជំនួយមានចំណង និងមានល័ក្ខខ័ណ្ឌគ្រប់បែបយ៉ាង» (sic) ។ យើងក៏ចង់ដឹងដែរថា ជាចំណងនិងជាល័ក្ខខ័ណ្ឌអ្វីទៅ ដែលស្តេចសីហនុមិនអាចទទួលបាននោះ ? ពីព្រោះយើង

ព្តែព្រះអង្គនិយាយដូច្នេះ តែមិនដែលបានឃើញឯកសារជាផ្លូវការទាល់តែសោះ ។ តើឯកសារនេះនៅឯណា ? និយាយអំពីអ្វី ? ល័ក្ខខ័ណ្ឌនោះយ៉ាងដូចម្ដេចដែរ ? ។ ចុះដល់ពេលស្ដេចសីហនុសំរេចទាត់ជំនួយមានចំណងនិងមានល័ក្ខខ័ណ្ឌអស់រយៈពេល៨ឆ្នាំនោះចោល ពុំមែនជាទង្វើល្មើសនឹងកិច្ចសន្យារបស់ខ្លួនទេឬ ? ។ ចំណុចនេះ ប្រជាពលរដ្ឋខ្មែរមិនទទួលយកបានទេ លុះត្រាណាបានឃើញ«ល័ក្ខខ័ណ្ឌ»ជាលាយល័ក្ខអក្សរទាំងអស់នោះជាមុនសិន ។ យើងពុំអាចយកតាម«ពាក្យសំដី»បង្ខិលរបស់ស្ដេចសីហនុ មួលខុសពីការពិតយ៉ាងដូច្នេះបានឡើយ ។

រឿងដែលគួរឲ្យចាប់អារម្មណ៍នោះ គឺការកាត់ផ្ដាច់ជំនួយអាមេរិកាំងនេះធ្វើឡើងនៅក្រោយទស្សនកិច្ចរបស់លោកប្រធានាធិបតីចិនលីវ-ចាវជី និងនៅក្រោយពេលសហរដ្ឋអាមេរិក បានអង្វរករសុំឲ្យស្ដេចសីហនុយល់ព្រមធ្វើជាសមាជិកនៃអង្គការ«សេអាតូ»បន្តិចប៉ុណ្ណោះ ។

ចាប់ពីចុងឆ្នាំ១៩៦៣រហូតមក ជំនួយពីខាងប្លុកកុម្មុយនិស្តក៏ហូរចូលមកក្នុងស្រុកខ្មែរដូចទឹកបាក់ទំនប់ ជាពិសេសជំនួយមកពីប្រទេសចិនប្រជាមានិត ។ សួរថា តើជំនួយពួកប្លុកកុម្មុយនិស្តនេះគ្មានចំណងនិងគ្មានល័ក្ខខ័ណ្ឌទេឬ ? ។ ភស្ដុតាងយ៉ាងច្បាស់ក្រឡែតមួយ គឺការអនុញ្ញាតឲ្យកងទ័ពយៀកកុង-យៀកណាមខាងជើង តាំងមូលដ្ឋានទ័ពនៅលើទឹកដីខ្មែរតាមបណ្ដោយព្រំដែនទិសខាងកើត ។ រួចហើយជំនួយនោះ ក៏ជួយហួសទៅកាន់ទីនោះអស់ទៅ... ១០%ខ្មែរក៏ស្ទើរតែមិនបានផង (!!)

ស្ដេចសីហនុយល់ថា នយោបាយអព្យាក្រឹត្យលំអៀងទៅខាងកុម្មុយនិស្ត រួចពន្យះឲ្យពួកនេះហក់ចូលមកឈ្លានពានស្រុកខ្លួនឯង រហូតបណ្ដាលឲ្យស្រុកខ្មែរក្លាយជា «ទីលានពិឃាត» នៃសតវត្សទី២០ ពុំមែនជារឿងអាម៉ាស់មុខ ប៉ះពាល់ដល់ឯករាជ្យ សេចក្ដីថ្លៃថ្នូរ និងកិត្តិយសជាតិទេ ។ តើហេតុអីស្ដេចសីហនុយល់យ៉ាងដូច្នេះ ? គ្មាននរណាយល់សោះឡើយ (!!)

នៅក្នុងអត្ថបទដដែល, ស្ដេចសីហនុចង្អុលបង្ហាញថា ៖ «ការកាត់ជំនួយនេះ បានធ្វើឲ្យពួកលន់ ណុន សិរិមតៈ ដែលមានសេអ៊ីអាជួយ សំរេចថាត្រូវធ្វើរដ្ឋប្រហារទម្លាក់ខ្ញុំនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ នៅក្នុងឱកាសដែលខ្ញុំកំពុងបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅសហភាពសូវៀត» (sic)។

គិតទៅស្ដេចសីហនុមាន«មូលហេតុ»របស់ព្រះអង្គ ច្រើនប្រការណាស់ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ថ្ងៃទី១៨មិនា១៩៧០ (!!)

តាមពិតទៅ ព្រឹត្តិការណ៍១៨មិនា១៩៧០ បានកើតឡើងប្រាំពីរឆ្នាំ(៧ឆ្នាំ)ឯណោះ ក្រោយពេលស្ដេចសីហនុប្រកាសកាត់ផ្ដាច់ជំនួយអាមេរិកាំង ។ ចំណុចដែលធ្វើឲ្យគេមិនជឿស្ដេចសីហនុនោះ គឺនៅត្រង់ថាជំនួយអាមេរិកាំងបានត្រូវរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមរបស់ស្ដេចសីហនុ (រដ្ឋាភិបាលប៉ែន-នុត) ទទួលឡើងវិញ កាលពីថ្ងៃទី១៩ កុម្ភៈ ឆ្នាំ១៩៦៨ (២ឆ្នាំមុនព្រឹត្តិការណ៍១៨ មិនា ១៩៧០) ។

ថ្ងៃទី២ មិនា ឆ្នាំ១៩៦៩, ស្ដេចសីហនុសំរេចប្រកាសឲ្យជាតិនិងអន្តរជាតិបានដឹងជាលើកដំបូង អំពីទីតាំងរបស់កងទ័ពយៀកកុង-យៀកណាមខាងជើង នៅលើទឹកដីខ្មែរ ។ ថ្ងៃទី២៨ មិនា ឆ្នាំ១៩៦៩, ស្ដេចសីហនុបានបង្ហាញឲ្យឃើញ នូវផែនទីយ៉ាងពិស្ដារមួយ អំពីទីតាំងរបស់កងទ័ពយៀកកុង-យៀកណាមខាងជើង (?!?!) ។

យើងក៏សូមឆ្ងល់ដែរថា តើការសុខចិត្តទទួលជំនួយសេដ្ឋកិច្ចនិងយោធារបស់អាមេរិកាំងលើកនេះ ជាការទទួលចំណងឬក៏ល័ក្ខខ័ណ្ឌអ្វីដែរឬទេ ។ ហើយតើការទទួលជំនួយលើកនេះ ទាក់ទងជាមួយលោកលន់-នល់និងទ្រង់សិរិមតៈហើយនិងសេអ៊ីអាដូចម្ដេចដែរទៅ ? យើងដឹងហើយថា ពុំមែនស្ដេចសីហនុជាអ្នកទទួលជំនួយទេ គឺលោកប៉ែន-នុតជានាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានស្ដេចសីហនុជាប្រមុខរដ្ឋទេតើ ដែលជាអ្នកទទួលនោះ (!!)

គ្រាន់តែទទួលជំនួយសេដ្ឋកិច្ចនិងយោធាអាមេរិកាំងភ្លាម ប្រទេសកម្ពុជាក៏បានក្លាយជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិផងដែរ ។

ក៏ប៉ុន្តែដែលច្របូកច្របល់គ្នានោះ, គឺនៅក្នុងពេលទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមរបស់ស្ដេចសីហនុ ក៏ទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន (រដ្ឋាភិបាលយៀកកុង) នៅ (ថ្ងៃទី១៣ មិថុនា ឆ្នាំ១៩៦៩) ។ មានន័យថា ៖ ម្ដងចង់ហែកមុខពួកយួនយៀកកុង, រួចមកងាកមកទទួលជំនួយអាមេរិកាំង និងចុងក្រោយទទួលស្គាល់រដ្ឋាភិបាលយួនយៀកកុង មុនពេលស្ដេចសីហនុប្រមូលប្រពន្ធកូន រៀបហិបហោញឡើងយន្តហោះរត់ចោលស្រុក (!!??) ។

ដើម្បីយល់ពីការប្រែប្រួលរបស់ស្ដេចសីហនុ សូមអានរាជសារចាស់របស់ស្ដេចសីហនុមួយទៀត សរសេរកាលពីថ្ងៃទី៦ មិនា ២០០៤ ដូចខាងក្រោមនេះ ៖

រាជសារ ព្រះករុណាព្រះបាទសម្ដេច
ព្រះនរោត្តម សីហនុ
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
ផ្ញើថ្វាយព្រះសង្ឃ និងជូនជនរួមជាតិ បងប្អូន កូនចៅ ចៅទួត
ជាទីគោរពរាប់អាន និងស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ប៉េកាំង ថ្ងៃទី៦ ខែមិនា ឆ្នាំ២០០៤

សូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ៗព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
សូមគោរពជនរួមជាតិ បងប្អូន កូនចៅ ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ថ្មីៗនេះ មាននិស្សិតជាតិយើងខ្លះបាននិយាយប្រាសចាកពីការពិត ដោយអយុត្តិធម៌ថាទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំភូតកុហក់ដោយអះអាងថាកម្ពុជាក្រោមការដឹកនាំរបស់សីហនុ មិនព្រមទទួលជំនួយអាមេរិកាំងទេ នៅក្នុងទសវត្ស៥០ និង៦០ ក្នុងឱកាសដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំជាប្រមុខរដ្ឋនៃរាជាណាចក្រកម្ពុជាទី១ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំសូមព្រះសង្ឃគ្រប់ៗព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជនរួមជាតិ បងប្អូន កូនចៅ ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត ព្រះមេត្តា និងមេត្តាផ្ដល់យុត្តិធម៌ដល់ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ ចំពោះការក្រឡៃការពិត ខុសស្រឡះពីប្រវត្តិសាស្ត្រដែលនិស្សិតខាងលើនេះបាននិយាយ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបានសរសេរចុះផ្សាយតាមប្រព័ន្ធអ៊ិនធ័រណែត និងក្នុងព្រឹត្តិប័ត្របេអិមដេជាច្រើនលើក ច្រើនគ្រា អំពីការមិនពេញចិត្តនឹងទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ ពីសំណាក់នាយទាហាន នាយទាហានរងនៃកងយោធពលខេមរភូមិន្ទ នៅពេលដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ សំរេចមិនទទួលជាបន្តទៀតជំនួយអាមេរិកាំង នៅឆ្នាំ១៩៦៣ ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបានសរសេរបញ្ជាក់ហើយ បញ្ជាក់ទៀតថាកម្ពុជាបានទទួលជំនួយអាមេរិកាំង (USA) តាំងពីទសវត្ស១៩៥០ រហូតមកដល់ឆ្នាំ១៩៦៣ ។

សូមព្រះសង្ឃគ្រប់ៗព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជនរួមជាតិ បងប្អូន កូនចៅ ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត ព្រះមេត្តា និងមេត្តាពិចារណាថាតើការសំរេចមិនទទួលជំនួយនេះមានន័យថារាជាណាចក្រកម្ពុជាទី១បានទទួលជំនួយពីអាមេរិកាំងដែរឬទេ ? បើមិនដែលបានទទួលជំនួយពីគេទេ តើធ្វើដូចម្ដេចបានជាទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំសំរេចកាត់ជំនួយនេះកើត ?

សូមសំដែងនូវអំណរព្រះរាជគុណ អំណរព្រះគុណ និងអំណរគុណជាអនេកប្បការ ។

ការបដិសេធរបស់ស្ដេចសីហនុថា ខ្លួនព្រះអង្គផ្ទាល់មិនបានទទួលជំនួយអាមេរិកាំងទេ គឺ«កម្ពុជា»ទេតើជាអ្នកទទួល គឺដូចគ្នានឹងការបដិសេធប្រព្រឹត្ត«អំពើសម្លាប់រង្គាល»ដូច្នោះដែរ ៖ ស្ដេចសីហនុពុំដែលសម្លាប់ដោយផ្ទាល់ដៃពីកាលណា គឺ«កម្ពុជាប្រជាធិបតេយ្យ»ទេតើ ដែលជាអ្នកប្រព្រឹត្តអំពើដ៏មហាឃោរឃៅព្រៃផ្សៃនោះ (!!) ។

សម្លេងខ្មែរនៅបរទេស

# សុំនិយាយផង!

★ តែមួយថ្ងៃសោះ ក្រោយពីធីបុណ្យសពលោកអតីតប្រធានាធិបតីសហរដ្ឋអាមេរិក រ៉ាណុល-រីហ្គិន, ស្ដេចសីហនុបានបញ្ចេញអត្ថបទពេបជ្រាយមួយនៅក្នុង<វ៉េបសាយ>របស់ព្រះអង្គ (ថ្ងៃទី១២មិថុនា២០០៤) មានចំណងជើងថា «មាសាំម អធិរាជនៃការធ្វើប្រព័ន្ធប្រជាធិបតេយ្យនៅក្នុងពិភពលោក» ។ ស្ដេចសីហនុបានខំរំលឹកឡើងវិញ កាលពីទសវត្សឆ្នាំ៥០-៦០ និង៧០ ដែលស្នាដៃរបស់<មាសាំម>ក្នុងការបំផុសបំផុលលទ្ធិប្រជាធិបតេយ្យនេះ បានធ្វើឲ្យខ្ទេចខ្ទាំដល់ប្រទេសវៀតណាមនិងកម្ពុជា ដោយព្រះអង្គមិននិយាយដល់ប្រទេសផ្សេងៗទៀតដូចជាប្រទេសឈីលី, ពួកប្រទេសនៅអាមេរិកឡាតាំង នៅអាហ្វ្រិក និងនៅអាស៊ីជាដើម ។ល។ ស្ដេចសីហនុសរសេរថា ៖ នៅវៀតណាម <មាសាំម> អធិរាជនៃលទ្ធិប្រជាធិបតេយ្យនេះបានបង្កើតជនផ្ដាច់ការឈ្មោះង៉ោ-ឌិនយ៉ីម (ហើយនិងក្រុមជនបិសាចង៉ោ-ឌិនញូ និងអ្នកស្រីញូ) ។ នៅកម្ពុជា គាត់បង្កើតជនផ្ដាច់ការឈ្មោះលន់-នល់ និងក្រុមបិសាចលន់-ណុន ។

★ ស្ដេចសីហនុបានស្ដីបន្ទោសដាក់កំហុស ទៅលើស្នាដៃរបស់<មាសាំម>ថា ជាមូលហេតុបណ្ដាលឲ្យមានព្រឹត្តិការណ៍១៧ មេសា ១៩៧៥ ដែលជាការចាប់ផ្ដើមនៃអំពើសម្លាប់រង្គាលរបស់ប៉ុល-ពត ។ «មិនត្រឹមតែប៉ុណ្ណឹងសោត», ស្ដេចសីហនុសរសេរ «មាសាំមគាត់មិនគិតជួយប្រជារាស្ដ្រខ្មែរទេ ផ្ទុយទៅវិញគាត់បានសំរេចចិត្តជួយទាំងខុស ចំពោះកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុល-ពត ឲ្យស្ថិតនៅជាសមាជិកនៃអង្គការសហប្រជាជាតិ ដែលជាអង្គការធានាគោរពសិទ្ធិមនុស្សថែមទៀតផង» ។

★ នៅក្នុងអត្ថបទរបស់ស្ដេចសីហនុខាងលើនេះ យើងពុំបានឮស្ដេចសីហនុមានបន្ទូល អំពីមុខនាទីរបស់ព្រះអង្គធ្វើជា«ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» ចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី២ មេសា ១៩៧៦ឡើយ ។ ហើយជាមួយគ្នាផងដែរ យើងក៏មិនឮស្ដេចសីហនុមានបន្ទូលអំពីការចូលរួមដៃជាមួយពួកយៀកកុង-យៀកណាមខាងជើង ដែលជាអំពើនាំភ្លើងសង្គ្រាមមកដុតផ្ទះឯង ។ យើងមិនឮបន្ទូលស្ដេចសីហនុអំពីតួនាទីរបស់ព្រះអង្គ ធ្វើជាប្រធានគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ចូលរួមក្នុងមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំនោះដែរសោះ ។ ជាពិសេសព្រះរាជដំណើរទស្សនកិច្ចទៅកាន់ពួកប្រទេសមួយចំនួននៃប្លុកកុម្មុយនិស្ដ ដើម្បីអួតអាងអំពីជោគជ័យដ៏មហាអស្ចារ្យមហាលោតផ្លោះនៃដំណើរបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យទេ ។ តើមកពីហេតុអ្វីដែរទៅ (??)

★ ស្ដេចសីហនុបានបញ្ចប់អត្ថបទ ដោយធ្វើការចំអកឡកលើយដាក់ <មាសាំម> អំពីស្នាដៃបង្កើតលទ្ធិប្រជាធិបតេយ្យនៅប្រទេសអៀរ៉ាក់ «ដែលតាមពិតទៅគឺជាការបផ្លិចបំផ្លាញប្រទេសនេះទាំងមូល», ស្ដេចសីហនុសរសេរ «រួចហើយបានធ្វើឲ្យប្រជារាស្ដ្រអៀរ៉ាក់ ធ្លាក់ទៅក្នុងសមុទ្រវេទនា និងការអាម៉ាស់» ។ វត្ថុបំណងដែលស្ដេចសីហនុសរសេរពេបជ្រាយដាក់អាមេរិកាំងនៅក្នុងពិធីបុណ្យសពលោកអតីតប្រធានាធិបតីនេះ គឺព្រះអង្គចង់ចូលរួមដៃបំបាក់មុខអាមេរិកាំង ជាមួយប្រធានាធិបតីបារាំង <ហ្សាក់-ស៊ីរ៉ាក់> ដែលពុំបានទៅចូលរួមនៅក្នុងពិធីបុណ្យសពឯរដ្ឋធានីវ៉ាស៊ិនតោនកាលពីថ្ងៃសុក្រ១១ មិថុនា ២០០៤ ។

★ ទង្វើដ៏<ឆ្កួតៗ>របស់នរោត្ដម-សីហនុនេះ គ្មាននរណាយល់ឡើយ ។ បុគ្គលនេះមិនស័ក្តិសមធ្វើជា<ស្ដេច>នៃប្រទេសកាន់ព្រះពុទ្ធសាសនា ដូចជាប្រទេសកម្ពុជានេះទេ ។ ទោះបីនរោត្ដម-សីហនុមិនចូលចិត្តសត្រូវចាស់របស់ខ្លួនយ៉ាងណាក្ដី គួរណាស់គាត់មានសីលធម៌នៅក្នុងខ្លួនខ្លះផង ។ ភាពកំរោលឃោរឃៅយង់ឃ្នងរបស់គាត់នេះ បានបង្ហាញឲ្យពិភពលោកបានឃើញយ៉ាងច្បាស់ណាស់ អំពីព្រឹត្តិការណ៍«សម្លាប់រង្គាល» នៅក្នុងស្រុកខ្មែរ ជាពិសេសនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលមាននរោត្ដម-សីហនុនេះជា «ប្រមុខរដ្ឋ» ។ តាមពិតទៅ ស្ដេចសីហនុនេះបានចងគំនុំសងសឹកឆេះក្ដៅគគុកនៅក្នុងដើមទ្រូងជាយូរមកហើយ, កំហឹងនេះបានផ្ទុះចេញមកយ៉ាងសាហាវបន្ទាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ។ ស្ដេចសីហនុជាមនុស្សរស់នៅក្នុងគំនុំនិងការសងសឹក (!!)

★ យើងនៅចាំអាកប្បកិរិយាថោកទាបរបស់នរោត្ដម-សីហនុ កាលពីថ្ងៃទី៩ ធ្នូ ឆ្នាំ១៩៦៣ ពេលព្រះអង្គចេញបញ្ជាទៅកាន់ប្រជាជាតិខ្មែរទាំងមូល ឲ្យអបអរសប្បាយ៣ថ្ងៃនឹងបុណ្យខ្មោចលោកប្រធានាធិបតីអាមេរិកាំង កេណ្ណឺឌី, ប្រធានាធិបតីយួនខាងត្បូងង៉ោ-ឌិនយ៉ីម និងនាយករដ្ឋមន្ត្រីថៃ សារិត-ថាណារ៉ាត ។ ប្រជាពលរដ្ឋខ្មែរស្រាប់តែងាកចិត្តគ្រប់គ្នា ចំពោះភាព<បាតផ្សារ>នៃព្រះប្រមុខរដ្ឋរបស់ខ្លួន ។ ជាការផ្ទុយទៅវិញ និងគួរឲ្យអស្ចារ្យក្រៃលែង ចំពោះខ្មោចហ៊ូ-ជីមិញ ដែលជាមេដឹកនាំចាំតែទំពារក្បាលខ្មែរ នរោត្ដម-សីហនុ ត្រឡប់ជានាំប្រពន្ធចុងទៅទួញយំសោកនៅចុងជើងខ្មោច ហើយមិនតែប៉ុណ្ណឹង គាត់ខំទៅនិមន្តព្រះសង្ឃជាន់ខ្ពស់ជាច្រើនអង្គ រួមដោយពួកនាម៉ឺនមន្ត្រីខ្មែរនានា តាំងរូបថតហ៊ូ-ជីមិញកណ្ដាលវាំងខ្មែរ ធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសផលល្អានិសង្សឲ្យថែមទៀតផង ។ នេះហើយ<សម្ដេចឪវា>, ណោរុងដ៏មហាពាលា (!!)...

★ ងាកមកមើលបញ្ហានយោបាយខ្មែរបច្ចុប្បន្នវិញ ។ <ការសម្ងាត់ខ្មែរ> (Khmer Intelligence) ម៉ាស៊ីនឃោសនាគណបក្សសម-រង្ស៊ី ចុះថ្ងៃទី១២មិថុនា២០០៤ ក្រោមចំណងជើងថា «ការបោះឆ្នោតកញ្ចប់តម្រូវការចូលរួមចំណែកពីព្រះមហាក្សត្រ» សរសេរថា ៖ ទោះបីការ<បោះឆ្នោតកញ្ចប់>នេះផ្ទុយនឹងរដ្ឋធម្មនុញ្ញយ៉ាងណាក៏ដោយ គេក៏អាចធ្វើការកែកុនបានដែរ នៅក្នុងពេលប្រទេសជួបវិបត្តិ ។ «ដើម្បីដោះស្រាយស្ថានភាពគ្រោះថ្នាក់ជាតិនេះបាន និងដើម្បីធានាដល់ដំណើរការប្រក្រតីនៃរដ្ឋាភិបាលទៅមុខបាន», ការសម្ងាត់ខ្មែរសរសេរ «គឺមានតែព្រះមហាក្សត្រទេ ដែលអាចកាត់សេចក្ដីដោយគ្មានកាន់បក្សពួកខាងណា និងជាទីសុខចិត្តនៃគ្រប់ៗគ្នា» ។ ចំពោះចំណុចនេះ, យើងយល់ថា ជាការល្អប្រសើរណាស់ គឺត្រូវមាន<ការចូលរួមចំណែកពីស្ដេចម្ចាស់ផែនទឹកផែនដី> មុនពេលសំពៅកម្ពុជាលិចស្រឹមទៅបាតសមុទ្រ ។ សំពៅខ្មែរដ៏រខេករខាកមួយនេះ ត្រូវតែមាននរោត្ដម-សីហនុជាអ្នកជួយបើកបរ ទោះបីព្រះអង្គខំប្រឹងចៀសវាងមិនព្រមធ្វើជា <កាពីតែន> ដ៏ក្លាហានមានការទទួលខុសត្រូវប្ដូរផ្ដាច់ជាមួយសំពៅរបស់ខ្លួន ដោយហ៊ានចងខ្លួនទៅនឹងចង្កូតសំពៅ ទោះបីត្រូវប្រឈមមុខជាមួយសភាពការណ៍ណាក៏ដោយ ។ តើធ្វើម្ដេចទៅហ្ន៎ បើនៅក្នុងពេលនេះនរោត្ដម-សីហនុកំពុងរត់ចោលសំពៅទៅ<ងរង៉ក់>នៅឯស្រុកឆ្ងាយរាប់យោជ ។ មើលចុះ ! សូម្បីតែចង់ឲ្យគេមកអបអរ<birthday>ប្រពន្ធចុងខ្លួនឯង ក៏ត្រូវ<ប៉ាវ>គេឲ្យទៅចូលរួមអបអរសាទរដែរ ពីព្រោះមកពីខ្លាចគ្មាននរណាគេទៅទេដឹង (!?)

★ យើងចង់ដណ្ដឹងសួរថា តើ<ប្រទេសជួបវិបត្តិ> ឬក៏មួយអស់លោ

កជួបវិបត្តិ (??) ។ បើនិយាយថា ពួកអស់លោកជួបវិបត្តិទៅ ប្រហែលដូចជាត្រឹមត្រូវជាង ពីព្រោះអីគណបក្សសម-រង្ស៊ី វាលែងជាទីសង្ឃឹមនៃពួកអ្នកគាំទ្រអស់រលីងទៅហើយ ។ ក្លាយជាគណបក្ស«បាតដៃ-ខ្នងដៃ» (flip-flop) រង់ចាំតែផឹកទឹកក្រោមកែងដៃគេ ជាគណបក្ស«ស៊ីឡាក» ដេករង់ចាំអ៊ុតមើលជើងខ្យល់ អំពីគណបក្សហ៊្វុនស៊ិនប៉ិចនឹងចែករំលែកកៅអីណាខ្លះមកឲ្យខាងខ្លួនប៉ុណ្ណោះ ? ដល់ដូច្នេះទៅ អំរែកកាន់តែធ្លាក់ធ្ងន់ទៅលើគណបក្សហ៊្វុនស៊ិនប៉ិច ពីព្រោះណាមួយត្រូវប្រឈមមុខការថែរក្សាកៅអីចាស់របស់ខ្លួនឲ្យគង់វង់ផង និងណាមួយទៀតត្រូវរកកៅអីជើងម៉ាបន្ថែមទៀត សំរាប់ចែករំលែកទៅឲ្យគណបក្សសម-រង្ស៊ី ដែលជាដៃគូនៅក្នុង<សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ>ផង ។ ទោះបីត្រូវគេចំអកថា<មិនចេះធ្វើលេខចែក> <មិនចេះធ្វើលេខសង>យ៉ាងណាក៏ដោយ ការទាមទារ ៥០/៥០ ជាយុទ្ធនាការថ្មី «គឺលែងគិតដល់លទ្ធផលឆ្នោតដែលប្រជារាស្ត្របោះឲ្យ»នោះទៀតហើយ ។ មានន័យថា ៥០ទៅខាងឯង ឯចំណែក៥០ទៀត អញត្រូវយកទៅចែកគ្នា២នាក់ (ចែកគ្នា២នាក់នេះ ក៏មិនដឹងថានឹងមានបញ្ហា ឬមួយក៏អត់ផង ?) ។ មកដល់ពេលនេះ អ្វីៗសុទ្ធតែ<ខុសច្បាប់>រួចអស់ទៅហើយ គេនាំគ្នាបន្តធ្វើខុសច្បាប់បន្តិចទៀតទៅមុខក៏មិនថ្មីដែរ ដូចជាការបោះឆ្នោតកញ្ចប់, បោះឆ្នោតកញ្ចើ, បោះឆ្នោតកន្ត្រក, បោះឆ្នោតស្បោងអីៗអស់ហ្នឹងជាដើម ។ល។ ម្នាក់ៗបានចំតិតចំតូងបន្ទោរបង់ដាក់លើ<ច្បាប់>រួចទៅហើយ ។ ពោលបើយើងត្រូវរត់ទៅជល់ក្បាលនឹងច្បាប់ មិនអាចរកច្រកចេញទៅទីណាបាន នោះយើងជា<ពួកមេដឹកនាំ>ស្រាប់ គ្មាន<អាអ៊ិនណា>ត្រួតពីលើក្បាលយើងទៀតទេ គឺយើងនឹង<កែប្រែច្បាប់>ដើម្បីសំរួលដំណើររបស់យើងទៅឈោងចាប់អំណាច ។ ទៅថ្ងៃមុខ បើយើងខ្វះលុយ យើងគឺជា<រដ្ឋ>ស្រាប់ នរណាហ៊ានថាអីយើង យើងនឹងនាំគ្នាបោះពុម្ពលុយឲ្យតែច្រើនថែមទៀតទៅ... ទៅណាវាល្បែង (!!) ។ ពួករាស្ត្រអស់ហ្នឹងគ្មានដឹងខ្យល់អីទេ ពួកយើងចង់ធ្វើអីក៏បានដែរ (!!)...។ សីហនុគឺកម្ពុជា... រាស្ត្រគឺរង្ស៊ី... បើរង្ស៊ីយល់ឃើញថា អាចបោះឆ្នោតកញ្ចិបកញ្ចប់បាន... នោះគឺគ្មានបញ្ហា (!!)

★ យើងបានសង្កេតឃើញថា នៅក្នុងអំឡុងពេលជិតមួយដណ្តប់ខែនៃការរាំងស្ទះនយោបាយនេះ អ្វីៗទាំងអស់បានហើយនិងកំពុងអនុវត្តទៅតាម «ទ្រឹស្តីរបស់រង្ស៊ី» (Rainsy's theory) ។ គាត់អាចរឹតខ្សែចាប៉ី ទៅតាមសម្លេងដែលគាត់ចង់បាន ៖ បើកាលណាធូរ គាត់បណ្តឹងបន្តិចទៅ ហើយបើកាលណាតឹងពេក គាត់ក៏បន្ធូរបន្តិចមេក ។ ឧទាហរណ៍ នៅពេលហៀបចេញលទ្ធផលឆ្នោត គាត់តវ៉ាអំពីភាពមិនប្រក្រតីនៅក្នុងការរាប់សន្លឹកឆ្នោត ដោយទាមទាររាប់ឆ្នោតពីរខេត្តឡើងវិញ ដែលជាខេត្តគាត់មានសន្លឹកឆ្នោតប្រកិតជិតគេ ។ ដល់ឃើញនៅតែតឹងមិនព្រម គាត់ក៏ទម្លាក់ចោល ហើយងាកទៅរករឿងជំទាស់ផ្សេងទៀត ។ នៅពេលស្តេចសីហនុបញ្ចេញ<សេណារីយ៉ូថ្ងៃទី៥វិច្ឆិកា២០០៣>ផ្អៀងទៅខាងហ៊ុន-សែន គាត់ក៏ផាក់ចោល តែដល់មកថ្មីៗនេះ ស្រាប់តែគាត់ចង់ទៅអែបអបស្តេចសីហនុឲ្យលើកមកអនុវត្តឡើងវិញ ។ គាត់និយាយថា «មានស៊ីអត់សែន-មានសែនអត់ស៊ី» តែដល់មកឥឡូវគាត់ថា «មានស៊ីមានសែន-មានសែនមានស៊ី» ។ គាត់ប្រកាសឡូងៗថា ការបោះឆ្នោតកញ្ចប់គឺជាអំពើរំលោភបំពានលើរដ្ឋធម្មញ្ញជាតិ តែដល់មកឥឡូវគាត់និយាយ គេអាចបោះបាននៅពេលស្រុកជួបប្រទះវិបត្តិ ។ ការចរចាកម្មវិធីនយោបាយក៏ជាការអនុវត្តន៍<ទ្រឹស្តី>របស់រង្ស៊ីមួយទៀតដែរ ។ តាមពិតទៅចំណុចទាំងអស់នោះមានដល់ទៅ១០០ឯណោះ បើបានតែ៧៣ក៏ជាការប្រសើរណាស់ ។ ថ្មីៗនេះរង្ស៊ីប្រកាសថា កិច្ចចរចាបានសំរេចជោគជ័យ៩៩ភាគរយ (៩៩%) ហើយ ទោះបីគ្រប់ៗគ្នាគ្មានឃើញអ្វីជាដុំកំភួនក៏ដោយ ជាពិសេសបញ្ហាលប់សន្ធិសញ្ញាព្រំដែនខ្មែរ-យួន, បញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ និងបញ្ហាប្រឆាំងអំពើពុករលួយ ។ ឥឡូវនេះគាត់ថា នៅសល់តែ១ភាគរយ(១%)ប៉ុណ្ណោះ ។ មួយភាគរយនេះ គឺបញ្ហាបែងចែកអំណាចគ្នា ។ ចំណុចនេះ រង្ស៊ីធ្លាប់បាននិយាយជាញឹកញាប់ថា ជាបញ្ហាមិនសំខាន់អ្វីទេ ...តែឥឡូវប្រែជាសំខាន់ខ្លាំងណាស់ (!!) ។ បញ្ហានេះមុខជានឹងក្លាយទៅជា <កម្មវត្ថុនៃការចរចាគ្នា>មួយថ្មីទៀត ពីព្រោះវាក៏ជាចំណុច<វិនិយោគទុន> ដែលគ្រប់ៗគ្នាបាន<ដាក់ផុក>ពីយូរមកហើយ ។ សួរថា តើ<ទ្រឹស្តីរបស់រង្ស៊ី> (Rainsy's Theory) ឬ<លទ្ធិរបស់រង្ស៊ី> (Rainsy's Doctrine) ឡប់អាចម៍ខ្សៀអស់នេះ នឹងចប់នៅពេលណាដែរ (??) ឬមួយក៏គេស្រុះគ្នានៅបន្តឡប់ៗតទៅមុខទៀត (??)

★ តើនរណាគិតថារឿងបែបនេះនឹងចប់ទៅងាយៗនោះ ? ។ តើគេនឹងមាន<កៅអី>ប៉ុន្មានសំរាប់ទុកលក់ ? ។ តើគេអាច<បូមលុយ>បានប៉ុន្មាន ? ។ តើគេមានវិធីយ៉ាងណាខ្លះ ដើម្បីអង្រួនពួកអង្គុយកៅអីចាស់ឲ្យជ្រុះលុយថែមទៀត ? ។ តើវិធីផ្លាស់ប្តូរកៅអី អាចមានប្រសិទ្ធិភាពក្នុងការរកលុយដែរឬទេ ? ។ បើពួកអ្នកបាត់បង់កៅអីខ្លាញ់មិនសប្បាយចិត្ត តើមានវិធីអ្វីសំរាប់ទប់ទល់ ? ។ ហេ ! នេះហើយជាបញ្ហាសំខាន់ (!!) ។ យើងបានដឹងរួចហើយ អំពីគណបក្សប្រជាជនកម្ពុជាគេចែកគ្នារស់ ចុះតែខាងហ៊្វុនស៊ិនប៉ិចនិងខាងសម-រង្ស៊ី នឹងចែកគ្នារស់ដែរឬទេ ? ។ តើពួកកំពុងរស់នៅក្រោមដើមក្រសាំងទាំងអស់នោះ ព្រះអង្គម្ចាស់រណឫទ្ធិនឹងគិតគូរយ៉ាងដូចម្តេចដែរ (??) ។

★ ព្រះរាជអត្ថបទថ្ងៃទី១៣មិថុនា២០០៤ ក្រោមចំណងជើងថា «ការមិនដឹងខ្លួន» (Inconscience) ស្តេចសីហនុសរសេរថា ៖ «មានពួកអ្នកនយោបាយជាន់ខ្ពស់និងពួកអ្នកគាំទ្ររបស់គេ កំពុងមានជំនឿយ៉ាងមាំថា សូម្បីតែនៅខាងក្រៅស្រុកខ្មែរ ក៏មានគេកោតសរសើរយ៉ាងខ្លាំង...កោតពី«ភាពចាស់ទុំ»របស់ពួកគេ (sic) » ។ ស្តេចសីហនុចំអកថា មើលទៅប្រហែលពួកគេយល់ថា បរទេសគេយល់ព្រមអំពីទង្វើរបស់ពួកគេ ក្នុងការទម្លាយ<ឯកទត្តភាព>ពិភពលោកខាងបញ្ហានយោបាយហើយ ។ «ពួកគេមានជំនឿយ៉ាងជ្រាលជ្រៅ», ស្តេចសីហនុសរសេរ «ពួកគេជឿថា ពួកគេពិតជាគិតដល់ផលប្រយោជន៍យ៉ាងសំខាន់របស់ស្រុកទេស ផលប្រយោជន៍របស់ជាតិ និងប្រជារាស្ត្រប៉ុណ្ណោះ ៖ រួចពុំបានគិតដល់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍បក្សពួករបស់ពួកគេនោះឡើយ» ។

«កាលណាពួកគេបញ្ឆោតខ្លួនគេ ដោយការបំភ័ន្តវិញ្ញាណនិងដោយជំនឿ នោះពួកគេមុខជាមិនបាត់បង់ការដេកមិនលក់បក់មិនល្ហើយ ស៊ីមិនបាន បាក់អំនួតនោះទេ ។ ជយោ !», ស្តេចសីហនុសរសេរ ។

★ ការបន្ត<ការព្រោកប្រាជ្ញ>របស់ស្តេចសីហនុនេះ វាប្រហែលសំខាន់ចំពោះព្រះអង្គ តែវាមិនសំខាន់សំរាប់ជាតិទេ ។ យើងចង់ដឹងថា តើចំពោះនរោត្តម-សីហនុវិញ តើព្រះអង្គ «ដឹងខ្លួន» ហើយឬនៅ (??) ឬមួយនៅតែមិនដឹងថា ព្រះអង្គជា<ស្តេចម្ចាស់ទឹកផែនដី> ដែលមានត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះព្រះនគរ (??) ។ តើហេតុអ្វីបានជាព្រះអង្គឈ្វេងយល់ថា ការ<ប៉ាវ>គេឲ្យនាំគ្នាជិះកប៉ាល់ឆ្លងកាត់សមុទ្ររាប់ពាន់គីឡូម៉ែត្រ ដើម្បីមកអបអរសាទរបុណ្យខួបកំណើតប្រពន្ធចុងខ្លួនឯងនៅវាំងបឹងអាយុវែង វាពុំមែនជា<ការបំភ័ន្តសតិ>ខ្លួនឯង (??) ។ តើការងរង៉ក់និរទេសខ្លួនឯង និងការកំហែងចង់ដាក់រាជ្យ<ពាក់កណ្តាល> (បើយោងតាមសំដីរបស់សម-រង្ស៊ី) វាប្រសើរឧត្តុងឧត្តមត្រង់កន្លែងណាទៅ (??) ។ តាមពិតនិងជាការផ្ទុយទៅវិញ... យើងមើលឃើញតែស្តេចសីហនុកំពុងកើតរោគ<វង្វេងវង្វាន់> ហើយគឺជាបុគ្គលកំពុងរវើរវាយអស់សង្ឃឹម ដេកមិនលក់បក់មិនល្ហើយ បាយមិនបាន និងបាក់អំនួត (!!)

សម្លេងខ្មែរនៅបរទេស

# តំរេះជិះកងឯមួយបែបផ្សេងទៀតរបស់សីហនុ !

ដោយ លី-ឡៀប ★ ថ្ងៃទី២០ មិថុនា ២០០៤

ស្តេចសីហនុកំពុងបន្តពេបជ្រាយរិះគន់នយោបាយអាមេរិកាំងនៅក្នុងប្រទេសអៀរ៉ាក់ ដោយធ្វើការប្រៀបធៀបទៅនឹងនយោបាយរបស់អាមេរិកាំងនៅក្នុងស្រុកខ្មែរ កាលពីជំនាន់ទសវត្ស៧០ ។ នៅក្នុងអត្ថបទចុះថ្ងៃទី១៨មិថុនា២០០៤ ស្តេចសីហនុសរសេរដោយមានខ្លឹមសារក្រៅផ្លូវការយ៉ាងដូច្នេះថា ៖

«យោងតាមបន្ទូលព្រះអង្គម្ចាស់ខ្មែរម្នាក់, សហរដ្ឋអាមេរិកត្រូវបន្តស្ថិតនៅក្នុងស្រុកអៀរ៉ាក់យូរតទៅមុខទៀត ពីព្រោះថាបើមាសាំមចាកចេញពីអៀរ៉ាក់ ស្រុកដ៏អភ័ព្វនេះ ពុំអាចចៀសរួចពីគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ និងគ្រោះថ្នាក់ស្លាប់ដូចប៉ុល-ពត ជារបៀបពួកឥស្លាមចុងពោចនិយមអារ៉ាប់បានឡើយ ។

ព្រះអង្គម្ចាស់ខ្មែរម្នាក់ទៀតធ្វើការកត់សម្គាល់ថា បើគ្មានអំពើរដ្ឋប្រហាររបស់លោកលន់-នល់និងសិរិមត: កាលពីថ្ងៃទី១៨មិនា១៩៧០ទេ និងបើគ្មានអំពើឈ្លានពានរបស់ចក្រពត្តិអាមេរិកាំងមកលើស្រុកខ្មែរ កាលពីខែមេសា-ឧសភា១៩៧០ទេ នោះស្រុកខ្មែរក៏មិនធ្លាក់ទៅក្រោមអំណាចរបស់ប៉ុល-ពតដែរ ។

កាលពីខែមិនា-មេសាឆ្នាំ១៩៧០, នៅទីក្រុងប៉េកាំង (សាធារណរដ្ឋប្រជាមានិតចិន), ពួកបញ្ញវ័ន្តខ្មែរក្រហម «ពួកអៀង-សារីនិយម» បាននិយាយថា ៖ «បើគ្មានអំពើរដ្ឋប្រហារប្រឆាំងសីហនុនៃលន់នល់-សិរិមត:ទេ, ពួកយើង (ខ្មែរក្រហម) ត្រូវធ្វើការតស៊ូយ៉ាងតិចណាស់ក៏ម្ភៃឆ្នាំទៀតឯណោះ ដើម្បីរំលាយសីហនុនិងសង្គមរាស្ត្រនិយម ។ គឺដោយសារមកពីលន់នល់-សិរិមត:នេះហើយ ទើបពួកយើងចំណេញបានម្ភៃឆ្នាំដែរក្នុងការប្រយុទ្ធរបស់យើងដើម្បីក្តាប់អំណាចនៅកម្ពុជា» (sic!) ។

ព្រះអង្គម្ចាស់ខ្មែរនិយាយនៅទីនេះថា «ជាដំបូង គេតែងតែមានការគោរពស្រឡាញ់គ្នាដូចលន់នល់-សិរិមត:និងចក្រពត្តិអាមេរិកាំង-អូស្ត្រាលីអញ្ចឹងហើយ, ព្រះអង្គម្ចាស់ខ្មែរនេះរំពឹងគិតថា ស្រុកអៀរ៉ាក់មុខជាក្លាយដូចស្រុកខ្មែរ កាលចន្លោះខែមិនា១៩៧០និងដើមខែមេសា១៩៧៥យ៉ាងដូច្នោះ, គឺជាស្រុក«ក្រោមអាណាព្យាបាល-អាណានិគម»របស់មាសាំមដ៏ជាទីគោរពសក្ការ:ពុំខានឡើយ ។ គិតទៅភាពស្មោះត្រង់គឺជាគុណសម្បត្តិដ៏គួរឲ្យកោតសរសើរមែន » ។

យើងបានដឹងថា ព្រះអង្គម្ចាស់ខ្មែរទាំងពីរអង្គដែលស្តេចសីហនុពុំបានបញ្ចេញឈ្មោះនេះ គឺគ្មាននរណាក្រៅអំពីទ្រង់សិរីវុឌ្ឍនិងទ្រង់បាណារ៉ាសិរិវ៉ុធនោះទេ ។ គិតទៅព្រះអង្គម្ចាស់ទាំងពីរនេះ ចេះធ្វើការប្រៀបធៀបដល់ម្លឹងផងឬ (??)

ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ វានៅតែជា«អត្ថបទ»របស់នរោត្តមសីហនុដដែលជាដដែលហ្នឹង ។ ល្បិចបែបនេះ អាចចាត់ទុកថាជាល្បិចចាស់ក៏បាន ឬមួយចាត់ទុកថាជា<ការសាកល្បងថ្មី>មួយបែបផ្សេងទៀតក៏បានដែរ ។

យើងសូមមិននិយាយអំពីប្រទេសអៀរ៉ាក់ទេ ពីព្រោះវាហួសសមត្ថភាពរបស់យើង ហើយវាក៏ពុំមែនជារឿងស្អីរបស់យើងផង ។ យើងសូមផ្តោតតែទៅលើ<បញ្ហារបស់ខ្មែរ>ប៉ុណ្ណោះ ៖

ស្តេចសីហនុបានលើកសំដីរបស់ព្រះអង្គម្ចាស់ខ្មែរម្នាក់និយាយថា គឺមកពីអំពើរដ្ឋប្រហាររបស់លន់នល់-សិរិមត: ទើបស្រុកធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ប៉ុល-ពត ។ ជាមួយគ្នានេះ, ស្តេចសីហនុបានរំលឹកឡើងផងដែរ នូវពាក្យសំដីរបស់ពួកបញ្ញវ័ន្តខ្មែរក្រហមអៀង-សារីនិយម និយាយគ្នានៅក្រុងប៉េកាំងកាលពីខែមិនា-មេសា១៩៧០ថា ៖ អំពើរដ្ឋប្រហារប្រឆាំងសីហនុរបស់លន់នល់-សិរិមត:នេះ នឹងធ្វើឲ្យពួកគេចំណេញម្ភៃឆ្នាំឯណោះ ដើម្បីកំចាត់ព្រះអង្គនិងសង្គមរាស្ត្រនិយម (!!)

ហេ ! គិតទៅម្យ៉ាងដែរតើមេវា (!!)

ចំណុចដ៏សំខាន់ជាងគេ ដែលយើងនឹងច្បិចយកចេញពីអត្ថបទនេះ គឺ «ខែមិនា-មេសា១៩៧០» ។ សួរថាតើហេតុអ្វីបានចំណុចពេលវេលានេះជារឿងសំខាន់ ? ។ ចម្លើយគឺថា ៖ បើស្តេចសីហនុបានស្តាប់ឮពួកបញ្ញវ័ន្តខ្មែរក្រហមអៀង-សារីនិយមផ្តោះផ្តងគ្នា អំពីផែនការរបស់ពួកគេ ចង់កំចាត់ព្រះអង្គនិងសង្គមរាស្ត្រនិយមយ៉ាងដូច្នេះដែរ... ចុះហេតុដូចម្តេចបានជាព្រះអង្គទៅបបួលពួក<សត្រូវ>របស់ព្រះអង្គអស់នេះ មកធ្វើការជាមួយគ្នានៅក្នុង «រណសិរ្សរួបរួមជាតិកម្ពុជា» និងនៅក្នុង «រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» ដែលព្រះអង្គជាអ្នកបង្កើតកាលពីថ្ងៃទី២៣ មិនា ១៩៧០ (??) ចុះហេតុអ្វីបានជានៅថ្ងៃទី២៣ មិនា ១៩៧០ដដែលនេះ ព្រះអង្គស្ទុះទៅចូលដៃជាមួយ «សត្រូវសួរពូជខ្មែរ» ពោលគឺពួកយៀកកុង-យៀកណាមខាងជើង (សន្ធិសិទទីក្រុងកង់តុង) ឲ្យពួកនេះលើកទ័ពទឹងក្នុងនាមរបស់ព្រះអង្គ ធ្វើការវាយប្រហារយ៉ាងសាហាវមកជនជាតិនិងប្រទេសរបស់ព្រះអង្គ (??) ។ តើហេតុអ្វីបាននរោត្តម-សីហនុមិនគិតថា «ការស្មោះត្រង់នេះជាគុណសម្បត្តិដ៏គួរឲ្យកោតសរសើរ» ផងទៅ ??

ព្រឹត្តិការណ៍១៨មិនា១៩៧០, បើតាមយើងដឹង មូលហេតុធំគឺបណ្តាលមកពីបញ្ហា «ពួកយៀកកុង-យៀកណាមខាងជើងក្រាញមិនព្រមដកថយចេញពីទឹកដីខ្មែរ» ហើយនិងពួកនេះពង្រីកសកម្មភាពកាន់តែសាយភាយរាលដាលធំឡើងៗនៅក្នុងស្រុកខ្មែរទាំងមូល ។ ស្តេចសីហនុទ័លដំរេះ ក៏ឲ្យលោកលន់-នល់ទទួលថ្នបាក់ជំនួសខ្លួន រួចនាំកូននាំប្រពន្ធរត់ចោលស្រុក ។ បើលន់នល់-សិរិមត:មានគំនិតក្បត់ ចុះចាំបាច់អ្វីត្រូវបញ្ជូនទ្រង់កន្តុល (តំណាងព្រះមហាក្សត្រីយានីកុសុម:) និងលោកយែម-សំបូរ (តំណាងរាជរដ្ឋាភិបាល) ទៅ<ពន្យល់អំពីស្ថានភាពនគរ>ដល់ព្រះអង្គនៅទីក្រុងប៉ារីស (ថ្ងៃទី១២មិនា១៩៧០) នាំឲ្យខាតពេលវេលាឥតប្រយោជន៍ធ្វើអ្វី (??) ។ គឺមកពីព្រះអង្គគុំចង់ក្លាយខ្លួនទៅជា <មហាវិរបុរសជាតិ>ដូចហូ-ជីមិញនោះហើយ ទើបស្រុកខ្មែរអន្តរធានបែបនេះ (!!)

តាមពិតទៅ, គ្មាននរណា<ក្បត់>ស្តេចសីហនុទេ គឺព្រះអង្គ<ក្បត់ជាតិ>ខ្លួនឯងទេតើ ៖ ព្រះអង្គបានចូលដៃជាមួយពួកយួនយៀកកុង-យៀកណាមខាងជើង, ព្រះអង្គចូលដៃជាមួយពួកខ្មែរក្រហម ហើយនៅថ្ងៃទី១៧មេសា ១៩៧៥ ព្រះអង្គបានឡើងធ្វើជា «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» ថែមទៀត ដែលជារបបសម្លាប់រង្គាលជនជាតិខ្លួនឯងយ៉ាងព្រៃផ្សៃអស្ចារ្យ និងដែលប្រវត្តិសាស្ត្រខ្មែរពុំដែលបានជួបប្រទះសោះឡើយ ។

យើងជឿថា អត្ថបទរបស់ព្រះអង្គនេះ វាពុំបានជួយអ្វីដល់ព្រះអង្គទេ ក្រៅអំពីជា «អន្ទាក់» ដែលព្រះអង្គធ្វើឡើង សំរាប់ទាក់កព្រះអង្គខ្លួនឯងប៉ុណ្ណោះ ។ ទង្វើដ៏អាស្រូវនេះប្រដូចសុភាសិតខ្មែរមួយពោលថា «ឈាមស្រែក-ស្បែកហៅ» ពុំខុសសោះឡើយ (!!) ។៚

សម្លេងខ្មែរនៅបរទេស

# ស្ដេចសីហនុនិងបញ្ហា ប្រទាក់ប្រទ្បសជាមួយខ្មែរក្រហម

ដោយ លី-ឌៀប ★ ថ្ងៃទី៣០ កក្កដា ២០០៤

ដើម្បីងាកចេញពីការស្ទីបឆ្មោសក្នុងការឡាយព្រះហត្ថលេខាលើ«រាជក្រឹត្យ»ត្រាស់ចាត់តាំងលោកហ៊ុន-សែន ធ្វើជានាយករដ្ឋមន្ត្រី ព្រមទាំងការប្រកាសទទួលស្គាល់រាជរដ្ឋាភិបាលអាណត្តិទី៣ ដែលជាអំពើរំលោភយ៉ាងធ្ងន់ធ្ងរទៅលើរដ្ឋធម្មនុញ្ញ នាថ្ងៃនេះ (៣០កក្កដា២០០៤) ស្ដេចសីហនុបានបង្វែអារម្មណ៍មតិជាតិនិងអន្តរជាតិ ទៅលើបញ្ហាផ្ទាល់ខ្លួនរបស់ព្រះអង្គដ៏ធ្ងន់ធ្ងរមួយទៀត គឺការជាប់ពាក់ព័ន្ធប្រទ្បាក់ប្រទ្បូសរបស់ព្រះអង្គ ជាមួយពួកមេដឹកនាំខ្មែរក្រហម នៅក្នុងអំពើសម្លាប់រង្គាលនិងអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ខាងក្រោមនេះជាអត្ថបទរបស់ស្ដេចសីហនុ ដែលយើងសូមបកប្រែក្រៅផ្លូវការដូចតទៅ ៖

«នៅក្នុងពេលខាងមុខមិនយូរនេះ, ស្រុកយើងនឹងមានតុលាការពិសេសខ្មែរ-អង្គការសហប្រជាជាតិមួយ ទទួលបន្ទុកធ្វើការកាត់ទោសពួកមេដឹកនាំខ្មែរក្រហម ដែលបានប្រព្រឹត្តកាលពីចន្លោះចាប់ពីខែមេសាឆ្នាំ១៩៧៥និងចុងឆ្នាំ១៩៧៨ នូវអំពើឧក្រិដ្ឋកម្មសម្លាប់រង្គាលជាតិ ។

រឿងនេះ ធ្វើឲ្យខ្ញុំនឹកដល់ការយល់ឃើញរបស់ខ្មែរនិងបរទេសខ្លះដែលគេថា អំពើឧក្រិដ្ឋកម្មដ៏ធំរបស់ខ្មែរក្រហម កាលពីថ្ងៃទី១៧ មេសា ១៩៧៥នេះ ពុំអាចធ្វើឲ្យរលំរលាយដល់របបលន់-នល់ និងពុំអាចឡើងក្ដាប់រដ្ឋអំណាចបានទេ បើប្រសិនណាគ្មានរូបខ្ញុំ ហើយនិងពួកសីហនុនិយមដែលជាអ្នករួមដៃមួយផ្នែកដ៏ធំនៃជនជាតិខ្មែរប្រុសស្រីទេនោះ ។

ចំពោះរឿងនេះ, ខ្ញុំកត់សម្គាល់អំពីតុលាការពិសេសខ្មែរ-អង្គការសហប្រជាជាតិ នូវហេតុការណ៍ពិតដូចតទៅ ៖

១- ពេញមួយជីវិតរបស់ខ្ញុំ ក្នុងរយៈពេល«សាធារណរដ្ឋខ្មែរ» តែងប្រកាសហើយប្រកាសទៀតថា នរោត្តម-សីហនុតំណាងឲ្យខ្លួនឯងប៉ុណ្ណោះ (sic) ពីព្រោះជាតិនិងប្រជារាស្ត្រខ្មែរលោកបដិសេធខ្ញុំចោលទាំងស្រុងរួចទៅហើយ (sic) ។

២- ពួកខ្មែរក្រហម, តាំងពីមុនមកពុំដែលបានអះអាងថានរោត្តម-សីហនុ ជាផ្នែកមួយនៃជ័យជំនះរបស់ពួកគេ ថ្ងៃទី១៧ មេសា ១៩៧៥ លើកម្ពុជាទេ ។ ពួកខ្មែរក្រហមបានយល់ស្របដូចពួកខ្មែរសាធារណរដ្ឋទាំងអស់នោះដែរបញ្ជាក់ថា នរោត្តម-សីហនុ ពុំមែនជាតំណាងបែបណានៃប្រជាពលរដ្ឋខ្មែរនោះឡើយ ។

បន្ថែមទៅលើព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ៖ ពួកខ្មែរក្រហមជាទូទៅបានធ្វើទារុណកម្មដល់ស្លាប់ ឬបានសម្លាប់ពួកសីហនុនិយមទាំងអស់ ឬពួកអ្នកដែលគេចោទថាជាជនប្រូសីហនុ ។

(កកន ៖ អង្គរបុរីបានចុះផ្សាយនូវសុន្ទរកថារបស់ស្ដេចសីហនុ តាមវិទ្យុចិនប៉េកាំងថ្ងៃទី២៣មិនា១៩៧០រួចហើយ ដែលនៅក្នុងនោះព្រះអង្គបានប្រកាសអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរ ឲ្យនាំគ្នាចូលព្រៃម៉ាគី ធ្វើការប្រឆាំងរបស់សាធារណរដ្ឋខ្មែរ និងការប្រកាសបង្កើត<រណសិរ្សនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា FUNK et GRUNK ផង ។ នៅក្នុងរណសិរ្សនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះ សមាជិកភាគច្រើនលើសលប់ គឺជាថ្នាក់ដឹកនាំខ្មែរក្រហម ។ គ្មានភស្តុតាងបង្ហាញការសម្លាប់ជនសីហនុទេ )

នៅក្នុងលក្ខណៈនេះ តើតុលាការអាចកាត់ទោសខ្ញុំដូចម្ដេចបានទៅចំពោះ«ការទទួលខុសត្រូវ» នៃការកាន់កាប់រដ្ឋអំណាចរបស់ប៉ុល-ពតព្រមទាំងពួកខ្មែរក្រហមរបស់គាត់? ក្នុងរឿងនេះ ខ្ញុំនឹងទៅបង្ហាញចំពោះមុខតុលាការ ដែលចោទជាសំនួរ ហើយខ្ញុំនឹងឆ្លើយ» ។

ការចង់បង្វែព្រឹត្តិការណ៍ខ្មែរ ឲ្យងាកទៅរកបញ្ហាមួយផ្សេងទៀត នៅក្នុងពេលខ្មែរមិនទាន់ឆ្លងផុតចំណោទនយោបាយជាតិនេះ វាធ្វើឲ្យយើងចាប់អារម្មណ៍ថា ស្ដេចសីហនុកំពុងមានបញ្ហាជំពាក់វាក់វិននៅក្នុងខ្លួនធំៗមួយចំនួន ដែលត្រូវដោះស្រាយ មុនឈានចូលទៅដល់ដំណាក់ការមួយថ្មីទៀត ។ ដំណាក់ការនៅខាងមុខនេះ ប្រហែល«ការដាក់រាជ្យ»ដែលព្រះអង្គតែងលើកយកមកជំអូញជំអែរវិលវិកនាពេលកន្លងមក ។

ខ្មែរជាអ្នកតាមដានស្ដេចសីហនុម្នាក់បាននិយាយប្រាប់<អង្គរបុរី>ថា ស្ដេចសីហនុប្រហែលអាចដាក់រាជ្យ ពីព្រោះព្រះអង្គគ្មានការជ្រើសរើសទៀតទេ ជាពិសេសប្រឈមមុខនឹងការវិវត្តន៍នាពេលថ្មីៗនេះ ។ ការចូលនិវត្តន៍ ឬការដាក់រាជ្យ នឹងធ្វើឲ្យស្ដេចសីហនុក្លាយជាប្រជារាស្ត្រសាមញ្ញដែលត្រូវបាត់បង់<អភ័យឯកសិទ្ធិ>ជា<ព្រះមហាក្សត្រ>បញ្ញត្តិតាមរដ្ឋធម្មនុញ្ញ ។ មុននឹងធ្វើដូច្នេះទៅបាន ស្ដេចសីហនុតោងជំរះខ្លួនព្រះអង្គឯងឲ្យជ្រះស្រឡះពីកំហុសផ្សេងៗ មានបញ្ហាជាប់ប្រទ្បាក់ប្រទ្បូសនៅក្នុងតួនាទីជា <អ្នកទទួលខុសត្រូវ> ជាមួយថ្នាក់ដឹកនាំខ្មែរក្រហម ចំពោះអំពើសម្លាប់រង្គាលនិងអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់ពីថ្ងៃទី១៧ មេសា១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨ នោះជាដើម ។

ការក្លាយខ្លួនជា<ប្រជារាស្ត្រសាមញ្ញ> អាចធ្វើឲ្យគេនាំខ្លួនព្រះអង្គចូលទៅក្នុងតុលាការខ្មែរ-អ.ស.ប.បាន ដែលមិនអាចការពារដោយមាត្រាទី៧នៃរដ្ឋធម្មនុញ្ញបានទេ ( មាត្រាទី៧ចែងថា ៖ ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រប់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។ ព្រះមហាក្សត្រទ្រង់ជាប្រមុខរដ្ឋមួយជីវិត ។ អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ) ។

ទោះបីការបង្ហាញហេតុផលខ្លះៗនៅក្នុងអត្ថបទរបស់ព្រះអង្គ ពុំគ្រប់គ្រាន់យ៉ាងណាក៏ដោយ ស្ដេចសីហនុក៏ត្រូវតែខំប្រឹងដែរ ។ ការពាក់ព័ន្ធរបស់ព្រះអង្គជាមួយថ្នាក់ដឹកនាំខ្មែរក្រហម ពុំមែនចាប់ផ្ដើមក្រោយថ្ងៃជ័យជំនះលើរបបសាធារណរដ្ឋខ្មែរ (១៧ មេសា ១៩៧៥) ដែលព្រះអង្គបានស្ម័គ្រចិត្តឡើងធ្វើជា «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» នោះឯណា ដំណើរការនយោបាយនិងការចូលរួមចំណែកយ៉ាងក្លៀវក្លារបស់ព្រះអង្គបានកើតមានឡើង ចាប់តាំងពីពាក់កណ្ដាលទសវត្សឆ្នាំ៦០មកម្ល៉េះ ។

ឯកសារជាច្រើននឹងចង្អុលទៅស្ដេចសីហនុ ដែលព្រះអង្គជាប្រធាននៃ<រណសិរ្សរួបរួមជាតិកម្ពុជា>, ប្រធាន<រាជរដ្ឋាភិបាលជាតិកម្ពុជា> និង<ប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ> ។ គឺមុខតំណែងចុងក្រោយនេះឯងហើយ ដែលជាចំណងចងស្ដេចសីហនុឲ្យជាប់ក្រញ៉ង់ នៅក្នុងសំបុកពីងពាងនៃអំពើសម្លាប់រង្គាលដ៏មហាព្រៃផ្សៃមួយនេះ ។

យើងយល់ថា «ការដាក់រាជ្យ»របស់ស្ដេចសីហនុនៅក្នុងពេលនេះពិតជាល្អប្រសើរណាស់ ពីព្រោះដើម្បីក្នុងការងាយស្រួលគេអូសកព្រះអង្គចូលទៅក្នុងតុលាការដើម្បីកាត់ទោស ។ ស្ដេចសីហនុពុំចាំបាច់រង់ចាំមើលបំណាំពី ទេព-វង់ នោះទេ។ គួរដាក់រាជ្យដោយខ្លួនតែម្ដងទៅ ។ ដល់ពេលនោះគេនឹងឃើញស្រុកខ្មែរ មានម៉ូនិកជា<និមិត្តរូបនៃរបបរាជានិយម ដែលមានប្ដីជា<អ្នកទោស>នៅក្នុងរឿងខ្មែរក្រហម ។៚

សម្លេងខ្មែរនៅបរទេស

# កាស៊ីណូរដ្ឋនៅភ្នំពេញ

ដោយ ឱប-គីមអាន

(ដកស្រង់ចេញពីទស្សនាវដ្តី<NEW CAMBODIA>
ឆ្នាំទី១ លេខ២ ខែមិថុនា ១៩៧០
(បកប្រែក្រៅផ្លូវការ)

«កាស៊ីណូរដ្ឋគឺបង្កើតឡើងជាឯកជនដោយសីហនុ-ម៉ូនិក-ប៉ោម និងបក្សពួករបស់គេ ក្នុងលេសម្ខាងដើម្បីរកប្រាក់ចំណូលបើកបៀវត្សឲ្យកងទ័ព និងម្ខាងទៀតដើម្បីរិះរកមធ្យោបាយដែលមិនអាចទៅរួច ក្នុងការបង្ក្រាបល្បែងស៊ីសងខុសច្បាប់ ដែលទាំងអស់នេះជាការបង្ហាញឲ្យឃើញ នូវបរាជ័យទាំងស្រុងនៃនយោបាយរបស់សីហនុ តាមរយៈការបង្កើតកាស៊ីណូរដ្ឋនេះ ។ ជាឧទាហរណ៍បន្ថែមពីលើពុតត្បុត និងគំនិតរវើរវាយរបស់ខ្លួន, សីហនុបានលើកផែនការនេះទៅសុំការអនុម័តពីសភាជាតិថែមទៀត ។

សីហនុគាត់គិតតែផលប្រយោជន៍គ្រួសាររបស់គាត់ ដោយគ្មានខ្វល់អំពល់អ្វីទាំងអស់ ចំពោះផលអាក្រក់ដែលកាស៊ីណូ នឹងផ្តល់ដល់ស្រុកទេសរបស់គាត់ ។

ល្បែងស៊ីសង, ទោះជាល្បែងផ្សងព្រេងសំណាង ឬជាល្បែងនៃមុខជំនាញយ៉ាងណាក៏ដោយ តែងបង្កើតឲ្យមានអារម្មណ៍ភ្ញាក់ផ្អើលនិងសប្បាយភ្លើតភ្លើន ព្រមទាំងរំដោះនូវកង្វល់នានា ។ ក៏ប៉ុន្តែ ការលេងល្បែងគ្មានផ្តល់នូវអ្វីល្អប្រសើរ ឬកិច្ចការអ្វីនោះទេ ។ នៅក្នុងករណីភាគច្រើនប្រាក់ទាំងអស់នៅក្នុងវង់ល្បែង តែងធ្លាក់ទៅលើដៃពួកមេបនប៉ុណ្ណោះ ។ នេះគឺជាលក្ខណៈទូទៅ ទទួលបានមកពីល្បែងស៊ីសង ដែលគ្មានអ្វីក្រៅអំពីការវង្វេងផុងខ្លួន និងការលែងធ្វើការងារចិញ្ចឹមជីវិតនោះទេ ។

នៅក្នុងផ្នែកពាណិជ្ជកម្មនិងឧស្សាហកម្ម សកម្មភាពគ្មានដំណើរការទៅមុខ ។ គេលែងទុកចិត្តគ្នា ។ ការខ្ចីបុលពុំអាចចៀសវាងរួច ។ អ្វីៗទាំងអស់ត្រូវប្រមូលលក់ដើម្បីយកលុយ ។ ក្រេឌីតត្រូវបាត់បង់ ។ គ្មាននរណាចង់គិតគូរការងាររកស៊ី ។ គ្រប់ៗគ្នាផ្តោតអារម្មណ៍តែទៅលើល្បែងស៊ីសងមួយមុខគត់ ។

នៅក្នុងសង្គម, ការផុសផុលជាច្រើនកើតមានឡើង ។ អំពើលួចប្លន់, អំពើឃាតកម្ម និងការធ្វើអត្តឃាតមានជាទូទៅ និងគ្មាននរណាយកចិត្តទុកដាក់ឡើយ ។ វិបត្តិគ្រួសារ ដូចជាលែងលះគ្នា និងលក់ផ្ទះសំបែងដែលជាទ្រព្យសន្សំ គឺមកពីមូលហេតុកាស៊ីណូ ។ មានករណីខ្លះ មនុស្សត្រូវរត់ចោលស្រុក, កំហែងយកលុយគេ, លួចបន្លំប្រាក់រដ្ឋដោយពួកអ្នករាជការ ដែលបណ្តាលមកតែពីការចាញ់កាស៊ីណូ ។

រូបភាពទាំងអស់នេះនឹងធ្វើឲ្យសង្គមទាំងមូល មានការប្រែប្រួលផ្លាស់ប្តូរ ។ ល្បែងស៊ីសងសឹងទៅជាគ្រឿងញៀន ជិតជាប់នៅក្នុងអារម្មណ៍ក្លាយជាការចាំបាច់ ។ តើការសប្បាយនេះ នឹងនាំមកនូវការឈឺចាប់ខ្លោចផ្សារអ្វីខ្លះទៅ ។

ចំនួនមនុស្សធ្វើការងារបានធ្លាក់ចុះ ។ ពេលវេលាសំរាប់បង្កើនភោគផល ត្រូវយកទៅចំណាយនៅក្នុងវង់ល្បែងស៊ីសងអស់ ។ ប្រពន្ធចូលកាស៊ីណូសិនមុនពេលទៅផ្សារ ។ ម្នាក់ៗសម្លឹងរកមើលជោគជតារាសី, រំពឹងលើការយលសប្តិ, បន់ស្រន់ខ្មោចព្រាយអារក្សអ្នកតា និងការកាត់ប្រផ្នូលផ្តេសផ្តាស ។ គេនាំគ្នាទស្សន៍ទាយរកមើលថ្ងៃមានលាភ ។ មានជួនកាល រហូតដល់ទៅបន់ព្រះសំពះអ្នកតាឲ្យចុះមកជួយថែមទៀតផង...

ផ្ទុយទៅវិញ ដើម្បីទប់ទល់នឹងអ្វីទាំងអស់នេះ, សីហនុបានចំណាយពេលវេលារបស់គាត់ ដើរថតកុននិងដើរចាយលុយ ក្នុងពេលប្រពន្ធរបស់គាត់ស្រវារលុយញាត់ហោប៉ៅ។ ការថតកុននិងការជប់លៀងថ្នាក់ដឹលុច បានត្រូវចាយវាយលុយអស់រាប់សិបលានរៀល ។ គេផឹកស៊ីអួរទីទួរ។ សីហនុកាន់តែចុកខ្លាញ់ រួចរត់ចេញទៅព្យាបាលនៅអឺរ៉ុប !

នេះហើយជាស្នាដៃរបស់សីហនុ ដែលមានជំនួយពីប្រពន្ធម៉ូនិក និងម្តាយក្មេកឈ្មោះប៉ោមរបស់គាត់» ។

★★★ គ្រួសារស្តេចសីហនុស្ទើរទាំងមូលតែម្តង ដែលនាំគ្នាបង្កើតអំពើអបាយមុខនេះ ។ សូម្បីតែព្រះមហាក្សត្រីយានីកុសុមៈ ក៏បានដាក់ផ្ទះជួល ឲ្យបើកធ្វើបនល្បែងស៊ីសងផងដែរ ។

ក្រៅពីទីក្រុងភ្នំពេញ, កាស៊ីណូរដ្ឋមានច្រើនកន្លែងទៀតដូចជា កែបបូកគោ និងក្រុងព្រះសីហនុ (សូមអានសៀវភៅ «មុនកម្ពុជា» <Before Kampuchea, Preludes to Tragedy> សរសេរដោយ Milton Osborne) ។ ប្រាក់អាស្រូវបានមកពីកាស៊ីណូរដ្ឋទាំងអស់នេះ កម្របានចូលទៅក្នុងហិបរដ្ឋណាស់ គឺធ្លាក់ទៅក្នុងដៃម៉ូនិកនិងយាយប៉ោមជាម្តាយ ព្រមទាំងក្លង់តែប៉ុណ្ណោះ ។ ជាញឹកញាប់, គេតែងលេចឮការឈ្លោះទាស់ទែងអំពីការចែកលុយគ្នានេះ ។ ឧទាហរណ៍ដូចជាជម្លោះរវាង គួរុន និងថៅ-សេង នៅក្នុងករណីកាស៊ីកែបជាដើម ។

ស្តេចសីហនុមិនត្រឹមតែបើកកាស៊ីណូរដ្ឋប៉ុណ្ណោះទេ គាត់ថែមទាំងធ្វើឲ្យស្រុកខ្មែរទាំងមូលក្លាយជា<វង់ល្បែងស៊ីសង>យ៉ាងធំទៀតផង ដែលជាអំពើមួយប្រឆាំងនឹងពុទ្ធសាសនាជាតិ ។ ព្រះអង្គបានអនុញ្ញាត ឲ្យប្រជារាស្ត្រខ្មែរលេងល្បែងស៊ីសង <បីថ្ងៃ-បីយប់> នៅរៀងឱកាសបុណ្យចូលឆ្នាំថ្មីម្តងៗ ។

នេះហើយជា «បរាជ័យ» នៃនយោបាយ<សង្គមរាស្ត្រនិយម>របស់ស្តេចសីហនុ ដែលត្រូវបញ្ចប់ដោយការរត់ចោលស្រុករបស់គាត់កាលពីដើមឆ្នាំ១៩៧០ ។

រាជរដ្ឋាភិបាលពីរចុងក្រោយបង្អស់នៃ<សង្គមរាស្ត្រនិយម> គឺរាជរដ្ឋាភិបាល<សំណាងចុងក្រោយ> និងរាជរដ្ឋាភិបាល <ស្រោចស្រង់ជាតិ> គឺជាលទ្ធផលសរុបនៃនយោបាយកសាងជាតិរបស់ស្តេចសីហនុ ។ គ្រាន់តែឮសូរឈ្មោះនៃរាជរដ្ឋាភិបាលទាំងពីរនេះ គេក៏អាចយល់បានអំពីរូបភាពទាំងមូលនៃស្រុកខ្មែរនាពេលនោះទៅហើយ ។ មានន័យថា ស្តេចសីហនុបានបង្ហិនបង្ហោចនគរខ្លួនឯង ដល់ថ្នាក់«វិនាសធុនក្ស័យ» មុនពេលទម្លាក់អំរែកដើរចេញ ទុកឲ្យលន់-នល់ទទួលថ្មបាក់ជំនួសខ្លួន ។

ដែលសាហាវនិងអាក្រក់អាក្រីជាងនេះទៅទៀតនោះ, ក្រោយពេលស្តេចសីហនុបានអនុញ្ញាតឲ្យពួកយៀកកុង-យៀកណាមខាងជើង ប្រើប្រាស់ទឹកដីក្នុងព្រំដែនទិសខាងកើត តាំងមូលដ្ឋានទ័ពរហូតបណ្តេញមិនចេញមក, នៅពេលលន់-នល់បណ្តេញពួកអស់នោះចេញ, ស្តេចសីហនុក៏ហក់ទៅចូលដៃជាមួយសត្រូវស្បូវជាតិថែមទៀត ដោយធ្វើការគៀងគរនិងពន្យុះឲ្យស្ទុះចូលមកកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរ ព្រមទាំងបំផ្លាញទ្រព្យសម្បត្តិខ្មែរស្ទើរពាយអស់មួយនគរ ។

យើងចង់ដឹងថា ៖ តើឲ្យលន់-នល់ត្រូវធ្វើដូចម្តេចទៅ ដើម្បីស្រង់ជាតិពី <វិនាសធុនក្ស័យ> ក្នុងពេលត្រូវប្រឈមមុខតតាំងសត្រូវដ៏ធំនិងដ៏មានកម្លាំងទ័ពទឹងយ៉ាងខ្លាំងអស្ចារ្យនេះ (??) ។៚

សម្លេងខ្មែរនៅបរទេស

# សីហនុខ្ចីដៃអ៊ីរ៉ាក់ វាយប្រហារអាមេរិកាំង!

ដោយ លី-ឌៀប ★ ថ្ងៃទី១៦ កញ្ញា ២០០៤

ទោះបីគិតមកដល់ពេលនេះជាង៣០ឆ្នាំទៅហើយក៏ដោយ ស្តេចសីហានុនៅតែចងគំនុំជាមួយអាមេរិកាំងដដែល សូម្បីព្រះអង្គបានសំរេចជោគជ័យកាលពីថ្ងៃទី១៧មេសា១៩៧៥ ដោយក្លាយជា«ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» រួចហើយយ៉ាងណាក៏ដោយ ។ ប្រទេសយួនដែលជាមហាមិត្តនិងជាមិត្តរួមអាវុធជាមួយស្តេចសីហានុ ធ្លាប់ប្រឡូកក្នុងសង្គ្រាមប្រឆាំងអាមេរិកាំងយូរអង្វែងឆ្នាំ និងសាហាវជាងស្តេចសីហានុទៅទៀតនោះ ក៏បានស្រុះស្រួលមូលមិត្តជាមួយសត្រូវចាស់របស់ខ្លួន រហូតដល់ត្រឡប់មកកៀកករកស៊ីជាមួយគ្នា និងប្រហែលគិតចង់ចូលរួមធ្វើសម្ព័ន្ធមិត្តនយោបាយជាមួយគ្នាថែមទៀតផង ។

រឿងដែលប្លែកនោះ គឺស្តេចសីហានុ ដែលឥឡូវនេះបានក្លាយជាព្រះមហាក្សត្រនៃប្រទេសកម្ពុជាទៅហើយ (សោយរាជ្យតែមិនគ្មានអំណាច) កំពុងលង់លក់នៅក្នុងសម័យសង្គ្រាមត្រជាក់ ហើយមិនព្រមភ្ញាក់រលឹកដើរឲ្យទាន់សម័យសង្គ្រាមសេដ្ឋកិច្ច និងសម័យបច្ចេកសាស្ត្របច្ចុប្បន្នដែលមានការវិវឌ្ឍន៍យ៉ាងលឿនស្លេវនេះសោះ ។

យួនគេឆ្លាតណាស់ គេគិតពីផលប្រយោជន៍របស់រាស្ត្រ និងរបស់ស្រុកគេជាធំ ។ គេអាចបត់បែនខ្លួនប្រាណស្របទៅតាមកាលៈទេសៈ ធ្វើយ៉ាងណាក៏ដោយ ឲ្យតែស្រុកគេបោះជំហានទៅមុខ ទាន់ប្រកិតៗគ្នាជាមួយប្រទេសនានានៅក្នុងភូមិភាគ ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ស្តេចសីហានុម្នាក់នេះ គាត់អត់ខ្វល់ទេ ដោយសារគាត់សំអាងថា គាត់ជាមនុស្សចាស់ជរាជិតស្លាប់ទៅហើយ ។ គាត់អត់<ម៉ុងហ្វ៊ំ>ថាតើប្រជារាស្ត្ររបស់គាត់ ស្រុកទេសគាត់ក្លាយទៅជាយ៉ាងឡើយ ឲ្យតែគាត់នៅសល់ឱកាសបានជេរអាមេរិកាំងឲ្យអស់កំហឹង ចេញពីដើមទ្រូងបានហើយ ។ នរណាចង់រិះគន់គាត់ ថាគាត់ជាស្តេចកញ្ជាស់ភ្លីភ្លើល្វីល្វើក៏ថាទៅ សីហានុនៅតែជាសីហានុដដែល គឺជា<សត្រូវប្រវត្តិសាស្ត្រ>របស់អាមេរិកាំង ។

សព្វថ្ងៃនេះ នៅក្នុងចំណោមពួកប្រទេសដាក់ទានជំនួយឲ្យខ្មែរ អាមេរិកាំងគឺជាម្ចាស់ទានដ៏ធំជាងគេទី២បន្ទាប់ពីជប៉ុន ។ ការធ្វើទានរបស់អាមេរិកាំងនេះ ពុំបានធ្វើឲ្យស្តេចសីហានុ ស្រាកស្រាន្តពីគំនុំគុំគួនឆ្កួតៗរបស់គាត់ឡើយ ។ ជារឿយៗ ស្តេចខ្មែរឡប់អាចម៍ខ្សៀនេះ បានសរសេរវាយប្រហារទៅលើនយោបាយនិងសកម្មភាពរបស់អាមេរិកាំង នៅជុំវិញពិភពលោកទាំងមូល ដោយគាត់តែងយកខ្លួនគាត់ទៅអែបជាមួយសត្រូវរបស់អាមេរិកាំងជានិច្ច ។

បើក្នុងកាលៈទេសៈនេះ ប្រទេសកម្ពុជាជាប្រទេសជឿនលឿន មានសេដ្ឋកិច្ចមាំមួននោះមិនថ្វីទេ តែជាស្រុកកំពុងសុំទានទេ ហើយសំបូរទៅដោយប្រជារាស្ត្រជាអ្នកសុំទានទៅទៀត រួមជាមួយបញ្ហាក្នុងស្រុកដ៏ច្រើនស្មុកស្មាញដូចអាចម៍ជាប់ឈ្នាងផង សម្លេងរបស់ស្តេចសីហានុដែលនៅក្នុងពេលនេះកំពុងនិរទេសខ្លួនឯង ផ្ញើខ្លួននៅតាមផ្ទះបរទេសនានាផងនោះ មិនខុសគ្នាពីសម្លេងឆ្កែលូ នៅពេលក្បួនអូដ្ឋកំពុងធ្វើដំណើរគ្រើនៗទៅមុខនោះឡើយ ។

ខាងក្រោមនេះជាលិខិតចំហរបស់ស្តេចសីហានុ ដែលយើងបានដកស្រង់ចេញមកពីកាសែត<កោះសន្តិភាព> ចុះថ្ងៃទី១៦កញ្ញា២០០៤ ៖

«កាលពីថ្ងៃទី១៥កញ្ញា២០០៤ ព្រះករុណាទ្រង់បានផ្ញើតាមវែបសាយរបស់ព្រះអង្គ នូវព្រះរាជសារលិខិតចំហមួយរបស់ព្រះអង្គ ដល់ពលរដ្ឋអ៊ីរ៉ាក់ ដែលកំពុងតែតស៊ូដើម្បីរំដោះប្រទេសអ៊ីរ៉ាក់ពីការកាន់កាប់បរទេស ដែលព្រះរាជសារលិខិតនេះ កោះសន្តិភាពសូមបកប្រែក្រៅផ្លូវការដូចតទៅ ៖

ខ្ញុំពុំភ្លេចហើយនិងពុំបំភ្លេចដាច់ខាត ដែលរវាងថ្ងៃទី១៨មីនា១៩៧០ (ថ្ងៃរដ្ឋប្រហាររបស់លន់-នល់និងបក្សពួក) និងថ្ងៃទី១៧មេសា១៩៧៥ ដែលប្រទេសរបស់លោកអ្នក ប្រជាជននិងមេដឹកនាំរបស់លោកអ្នក ពុំបានបោះបង់រូបខ្ញុំចោលឡើយ ហើយបានផ្តល់ការគាំទ្រជាផ្លូវការចំផុតចំពោះរូបខ្ញុំ (ទទួលស្គាល់ខ្ញុំជាប្រមុខរដ្ឋស្របច្បាប់ជានិច្ច និងបានគាំទ្រម៉ឺងម៉ាត់ ចំពោះប្រជាជនកម្ពុជាស្នេហាជាតិ ក្នុងការតស៊ូរបស់ខ្លួន ដើម្បីរំដោះជាតិ ហើយការគាំទ្រនោះមានរហូតដល់យើងបានទទួលជោគជ័យចុងក្រោយ ។

(កកន ៖ តាមធម្មតាស្តេចសោយរាជ្យនៃនគរមួយ គេពុំដែលធ្វើលិខិតចំហទៅកាន់ប្រជារាស្ត្រនៃនគរមួយទៀត ដែលពុំដឹងថាមានប្រជារាស្ត្រនៃនគរនោះប៉ុន្មានគ្រាប់ បានដឹងពីវែបសាយរបស់ខ្លួនយ៉ាងដូច្នេះទេ ។ ស្តេចសីហានុគួរជ្រើសរើសនូវមេក្រុមបះបោរណាមួយ នៅក្នុងចំណោមប្រជារាស្ត្រអ៊ីរ៉ាក់ទាំងអស់នោះ ។ តើមេដឹកនាំរដ្ឋាភិបាលអ៊ីរ៉ាក់សព្វថ្ងៃនេះ ជាតំណាងប្រជារាស្ត្រដែលធ្លាប់គាំទ្រព្រះអង្គពីមុននោះ ក៏ស្តេចសីហានុមិនអាចដឹងបានដែរ ពីព្រោះស្ថានភាពនៅអ៊ីរ៉ាក់បានផ្លាស់ប្តូរទាំងស្រុងអស់ទៅហើយ ។ លេសរបស់ស្តេចសីហានុ គឺគាត់ចង់តែនៅខាងណាដែលប្រឆាំងអាមេរិកាំងប៉ុណ្ណោះ ។ ខាងណាប្រឆាំងនឹងអាមេរិកាំង គឺជាមិត្តរបស់គាត់ទាំងអស់ ។ ស្តេចនេះគាត់ចូលដៃតែជាមួយមនុស្សអាក្រក់ៗទេ ដូចជាសាដាម-ហូស្សាំងជាដើម ដែលជាជនផ្តាច់ការនិងជាមេឃាតករសម្លាប់រាស្ត្រខ្លួនឯង។ លក្ខណៈរបស់សាដាមនិងស្តេចសីហានុមិនជាខុសគ្នាប៉ុន្មានទេ ក្លិនឈាមប្រឡាក់បាតដៃក៏ប្រហែលគ្នា ។ ស្តេចសីហានុជាមេខ្មែរក្រហម និងបន្ទាប់មកបានឡើងធ្វើជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងលិខិតចំហ, ស្តេចសីហានុសរសេថា ប្រជារាស្ត្រអ៊ីរ៉ាក់ (ប្រហែលពួកខាងប្រឆាំងអាមេរិកាំង) ទទួលស្គាល់ព្រះអង្គជាប្រមុខរដ្ឋស្របច្បាប់ ចាប់ពីថ្ងៃ១៨មិនា១៩៧០ រហូតដល់ថ្ងៃទី១៧មេសា១៩៧៥ ។ យើងសូមឆ្ងល់ថា បើមានបរទេសទទួលស្គាល់ថាព្រះអង្គនៅតែជាប្រមុខរដ្ឋស្របច្បាប់យ៉ាងដូច្នេះទៅហើយ ចុះហេតុអ្វីបានជាព្រះអង្គទៅបង្កើត<រណសិរ្សរួបរួមជាតិកម្ពុជា> និងបង្កើត<រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា> ហើយតើហេតុអ្វីបានជាប្រជារាស្ត្រអ៊ីរ៉ាក់មិនបន្តទទួលស្គាល់ព្រះអង្គជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីថ្ងៃទី១៧មេសា១៩៧៥ ?) ។

ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទី២ ខ្ញុំ (នរោត្តម-សីហនុ) ពេលនេះមានព្រះជន្មកាន់តែចាស់ណាស់ទៅហើយ (៨២ព្រះវស្សា) មានមហាកិត្តិយសសំដែងនូវការគាំទ្រចំពោះលោកអ្នក ក្នុងការតស៊ូដ៏ត្រឹមត្រូវរបស់លោកអ្នក ដើម្បីប្រទេសអ៊ីរ៉ាក់មួយដែលមានឯករាជ្យពេញលេញ គ្មានវត្តមានរបស់កងទ័ពនិងអាជ្ញាធរបរទេស ។

(កកន ៖ តែផ្ទុយទៅវិញ ស្តេចសីហានុបានអនុញ្ញាតឲ្យកងទ័ពបរទេសចូលមកប្រើប្រាស់ទឹកដីស្រុករបស់ខ្លួន ធ្វើជាមូលដ្ឋានកងទ័ព និងមិនតែប៉ុណ្ណឹងសោត នៅឆ្នាំ១៩៧០ ស្តេចនេះរហូតដល់ទៅគៀងគរនិងពន្យុះកងទ័ពបរទេសនេះ ឲ្យធ្វើការវាយប្រហារទៅលើស្រុកខ្លួនឯងទៀតផង ។ មកដល់ឆ្នាំ១៩៨៣ ស្តេចសីហានុក្នុងនាមជាប្រធានឧត្តមក្រុមប្រឹ-

ក្សាជាតិ បានប្រគល់<អធិបតេយ្យភាព>ប្រទេសកម្ពុជា ទៅឲ្យអាជ្ញាធរអង្គការសហប្រជាជាតិ ដែលប្រកបដោយកងទ័ពចំរុះមកពីប្រទេសជាច្រើនជុំវិញពិភពលោក ចូលមកត្រួតត្រារៀបចំស្រុកខ្មែរឡើងវិញ ក្រោមប-ន្ទាប់ពីនយោបាយឡប់អាចម៍ខ្សៀរបស់ព្រះអង្គ ម្តងទៅគៀរយួនឲ្យចូលឈ្លានពានស្រុកខ្មែរ បង្កើតខ្មែរខ្មែរក្រហមកាប់សម្លាប់ខ្មែរ និងម្តងហាក់ទៅបណ្តេញយួនឲ្យចេញទៅវិញ (ទសវត្សឆ្នាំ៨០) រួចនៅទីបំផុតហាក់ទៅត្រូវរ៉ូវចាក់ចេកចាក់ស្គរគ្នាជាមួយពួកអាយ៉ងយួន ) ។

ទាក់ទិនដល់សាសនាអ៊ីស្លាម យើងប្រជាជនកម្ពុជា (ព្រះមហាក្សត្រ និងប្រជាជន) ពីជំនាន់មួយទៅជំនាន់មួយ យើងតែងគាំទ្រជានិច្ចចំពោះសាសនាអ៊ីស្លាម ហើយការពារអ្នកកាន់សាសនាអ៊ីស្លាមនៅប្រទេសយើង ហើយសាសនានោះ គឺជាសាសនាទី២របស់រដ្ឋយើង ។

ចំពោះបញ្ហានៃការប្រើស្បៃអ៊ីស្លាមក្នុងសាលារៀនទាំងឡាយរបស់យើង ក៏គ្មានបញ្ហាណាមួយដែរ ។ រដ្ឋកម្ពុជារបស់យើងគោរពជានិច្ច ១00% ចំពោះទំនៀមទំលាប់ប្រពៃណីនិងច្បាប់ក្បួនទាំងឡាយ របស់ជនមូស្លីមទាំងអស់នោះនៅកម្ពុជា ។

( កកន ÷ កាលជំនាន់ឆ្នាំ៥0និង៦0 ពេលខ្ញុំរៀនសូត្រនៅសាលារៀន ខ្ញុំមានមិត្តភក្តិស្រីចាមជាច្រើន តែខ្ញុំពុំដែលឃើញនាងទាំងអស់នោះពាក់ស្បៃទៅរៀនទេ ។ មកដល់ថ្ងៃនេះ នៅភាគខាងត្បូងរដ្ឋកាលីហ្វ័រនិញ៉ាសហរដ្ឋអាមេរិក ដែលជាតំបន់សំបូរទៅដោយអ្នកកាន់សាសនាមូស្លីម ខ្ញុំឃើញជនជាតិអាមេរិកាំង ពុំដែលរើសអើងឡើយ ។ ខ្ញុំឃើញអ្នកទាំងអស់នោះទទូរស្បៃដើរពេញផ្លូវ គ្មាននរណារំខានអ្វីទេ ។ ជាពិសេសជនជាតិអាមេរិកាំងស្បែកខ្មៅ សំបូរអ្នកកាន់សាសនាមូស្លីមទៀតផង ។ ហេតុដូច្នេះអាមេរិកាំងមិនល្អជាងបារាំងទេឬ ដែលគ្មានទ័ពនៅអ៊ីរ៉ាក់ ? ) ។

ក្នុងសារលិខិតរបស់ខ្ញុំនេះ ដោយមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់អ៊ីរ៉ាក់ ខ្ញុំសូមស្នើដល់លោកអ្នកនូវការអនុញ្ញាតិ បង្ហាញជូនលោកអ្នកនូវសំណើតែ២ប៉ុណ្ណោះគឺ ÷

ក- សូមលោកអ្នកបោះបង់ចោលការធ្វើទារុណកម្ម និងសម្លាប់ចំ-ណាប់ខ្មាំងរបស់លោកអ្នក ដោយការបោះបង់បែបនេះនឹងបំរើដល់ផលប្រយោជន៍យ៉ាងខ្ពង់ខ្ពស់របស់លោកអ្នកនៅលើឆាកអន្តរជាតិ ហើយនិងអាចជួយជំរុញឲ្យបុព្វហេតុរំដោះប្រទេសអ៊ីរ៉ាក់អាចសំរេចបានឆាប់រហ័ស ។

( កកន ÷ បើគ្មានការវាយប្រហាររបស់យៀកកុង-យៀកណាមខាងជើងមកលើស្រុកខ្មែរ, បើគ្មានអំពើសងសឹកទៅលើជនសាធារណរដ្ឋពីក្រុមខ្មែរក្រហមរបស់ស្តេចសីហនុ ក៏ស្រុកខ្មែរពុំអន្តរធានដូចសព្វថ្ងៃនេះដែរ ។ រឿងនេះស្តេចសីហនុជាអ្នកទទួលខុសត្រូវដ៏ធំជាងគេនៃប្រវត្តិសាស្ត្រខ្មែរ ។ ដូច្នេះដោះស្រាយតែរឿងផ្ទៃក្នុងខ្លួនឯងឲ្យជ្រះស្រឡះទៅបានហើយ ជាពិសេសការកាត់ទោសពួកបនខ្មែរក្រហម និងការរៀបចំខ្លួនរបស់ព្រះអង្គ ដើម្បីឲ្យគេកាត់ទោស ។ រឿងរបស់អ៊ីរ៉ាក់គឺជារឿងតូចតាច និងក៏គ្មានអ្វីទាក់ទងជាមួយស្រុកខ្មែរដែរ ! ) ។

ខ- សូមលោកអ្នកដោះលែងគេដោយគ្មានលក្ខខណ្ឌ នូវចំណាប់ខ្មាំងជនជាតិបារាំង និងចំណាប់ខ្មាំងនៃប្រទេសដទៃៗទៀត ដែលប្រទេសរបស់ពួកគេពុំមានកងទ័ពនៅក្នុងប្រទេសអ៊ីរ៉ាក់ ។ បញ្ហានៃការប្រើស្បៃក្នុងសាលារៀនទាំងឡាយរបស់បារាំង មិនត្រូវក្លាយទៅជាបញ្ហាធ្ងន់ធ្ងរមួយដូចជាបញ្ហានៃការរក្សាទុកកងទ័ពបរទេសនៅអ៊ីរ៉ាក់ឡើយ ។

( កកន ÷ ស្តេចសីហនុចង់មានន័យថា ចាប់តែជនជាតិអាមេរិកាំងទៅបានហើយ... បរាជ័យទៅចក្រពត្តិនិយមអាមេរិកាំងនិងបរិវាររវា !) ។៚